00212456

A190/II/5

នៅចំពោះមុខអង្គបុរេជំនុំជម្រះ
អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

| | | |
|---|---|---|
| សំណុំរឿងលេខ | ៖ | ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ-១២) |
| កាលបរិច្ឆេទនៃឯកសារ | ៖ | ថ្ងៃទី១៥ ខែសីហា ឆ្នាំ២០០៨ |
| ភាគីបញ្ជូន | ៖ | ការិយាល័យសហព្រះរាជអាជ្ញា |
| ភាសាដើម | ៖ | អង់គ្លេស |
| ប្រភេទឯកសារ | ៖ | សាធារណៈ |

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 15 / AUG / 2008
ម៉ោង (Time/Heure): 15 : 00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

# ចម្លើយតបរបស់ សហព្រះរាជអាជ្ញា
# ទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ស្តីពី
# សិទ្ធិ និង ភាតព្វកិច្ចរបស់ភាគី ទាក់ទងនឹងការបកប្រែ

**បញ្ជូនដោយ៖**

**ការិយាល័យហាព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង

លោក Robert PETIT

លោក យ៉េត ចរិយា

លោក William SMITH

លោក តាន់ សេណារ៉ុង

លោក Anees AHMED

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 19 / 08 / 2008
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

**ចែកចាយជូន៖**

**អង្គបុរេជំនុំជម្រះ៖**

ចៅក្រម ប្រាក់ គឹមសាន

ចៅក្រម Rowan DOWNING

ចៅក្រម ន័យ ថុល

ចៅក្រម Katinka LAHUIS

ចៅក្រម ហួត វុទ្ធី

**មេធាវីការពារក្តីរបស់ អៀង សារី៖**

លោក អាង ឧត្តម

លោក Michael G. KARNAVAS

## ១. សេចក្ដីផ្ដើម

១. នៅក្នុងសេចក្ដីសម្រេចមួយ ដែលពណ៌នាអំពីសិទ្ធិ និងកាតព្វកិច្ចរបស់ភាគីទាក់ទងនឹងការបកប្រែក្នុងអំឡុងពេលនៃការស៊ើបសួរ ("សេចក្ដីសម្រេចទាក់ទងនឹងការបកប្រែ") សហចៅក្រមស៊ើបអង្កេតបានចេញដីកាសម្រេចថា គេត្រូវផ្ដល់ជូនដល់ជនត្រូវចោទជាភាសាដែលជនត្រូវចោទយល់បាននូវ៖ ទី១) ដីកាបញ្ជូនរឿងទៅជំនុំជម្រះដោយមានធាតុផ្សំជាភស្តុតាង ដែលជាមូលដ្ឋាននៃដីកាបញ្ជូនរឿងទៅជំនុំជម្រះនោះ និងទី២) ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ និងដីកាសន្និដ្ឋានស្ថាពរ ដោយមានលិខិតក្រមនៃធាតុផ្សំអង្គហេតុ ដែលជាមូលដ្ឋាននៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ និងដីកាសន្និដ្ឋានស្ថាពរ[1] ។ ដោយកត់សម្គាល់ឃើញថា សមត្ថភាពក្នុងការបកប្រែរបស់ផ្នែកគ្រប់គ្រងតុលាការមានកំណត់ សហចៅក្រមស៊ើបអង្កេតបានតម្រូវផងដែរថា ក្រុមមេធាវីការពារក្ដីត្រូវកាត់បន្ថយតម្រូវការនៃការបកប្រែរបស់ខ្លួន ដោយប្រើប្រាស់នូវសមត្ថភាពផ្នែកភាសាវិទ្យានៅក្នុងក្រុមរបស់ខ្លួន និងនៅក្នុងផ្នែកគាំទ្រការការពារមេធាវី[2] ។ សហចៅក្រមស៊ើបអង្កេត ក៏បានបង្គាប់ផងដែរថាគេត្រូវផ្ដល់អ្នកបកប្រែណាម្នាក់ដោយមិនគិតកម្រៃ ឲ្យផ្ដល់សេវាដល់ក្រុមការពារក្ដីនីមួយៗ[3] ។

២. ជនត្រូវចោទឈ្មោះ អៀង សារី ស្វែងរកការបដិសេធសេចក្ដីសម្រេចទាក់ទងនឹងការបកប្រែ ដោយលើកជាសំអាងថា៖ ទី១) វាបំពានលើសិទ្ធិចូលរួមនៅក្នុងការការពារក្ដីរបស់គាត់ ដោយមិនបានផ្ដល់ដល់រូបគាត់នូវគ្រប់ឯកសារទាំងអស់ជាភាសាខ្មែរ ដែលត្រូវដាក់នៅក្នុងសំណុំរឿង, ទី២) បំពានលើសិទ្ធិមានអ្នកតំណាងផ្នែកច្បាប់ការពារក្ដីរបស់គាត់ ដោយមិនបានផ្ដល់ដល់រូបគាត់នូវឯកសារទាំងនោះជាភាសាអង់គ្លេស ដែលជាភាសារបស់ក្រុមមេធាវីការពារក្ដី

---

[1] *ករណីរបស់ អៀង សារី,* ដីកាសម្រេចរបស់ ក.ស.ច.ស ស្ដីពី សិទ្ធិ និង កាតព្វកិច្ចរបស់ភាគី ទាក់ទងនឹងការបកប្រែ, សំណុំរឿងព្រហ្មទណ្ឌលេខ៖ ០០២/១៤-០៨-២០០៦ ចុះថ្ងៃទី២៣ មិថុនា ២០០៨, លេខERN 00196923-00196930, A/90 កថាខណ្ឌ B4 [*បន្ទាប់ពីនេះទៅហៅថា៖* សេចក្ដីសម្រេចទាក់ទងនឹងការបកប្រែ] ។

[2] សេចក្ដីសម្រេចទាក់ទងនឹងការបកប្រែ, កថាខណ្ឌ A4 ។

[3] សេចក្ដីសម្រេចទាក់ទងនឹងការបកប្រែ, កថាខណ្ឌ B2-B3 ។

00212458

A190/II/5



អន្តរជាតិរបស់គាត់, និងទី៣) បំពានលើសមភាពនៃអំណាច [រវាងការដាក់ និងដោះបន្ទុក] ដោយការបំបែរបន្ទុកនៃការបកប្រែ ពីសមត្ថកិច្ចតុលាការនេះឲ្យទៅខាងអង្គភាពគាំពារការការពារក្តីទៅវិញ[4] ។

៣. សហព្រះរាជអាជ្ញា ស្នើឲ្យ អង្គបុរេជំនុំជម្រះ បដិសេធបណ្តឹងឧទ្ធរណ៍នេះចោល ។ បណ្តឹងឧទ្ធរណ៍នេះមិនអាចទទួលយកបានទេ ព្រោះថា សេចក្តីសម្រេចទាក់ទងនឹងការបកប្រែនេះ មិនមែនជាសេចក្តីសម្រេចមួយដែលស្ថិតនៅក្នុងប្រភេទទាំងឡាយ ដែលបានកំរិតឱ្យជនត្រូវចោទអាចប្តឹងឧទ្ធរណ៍ទៅអង្គបុរេជំនុំជម្រះបាននោះទេ[5] ។ បើមិនដូច្នោះទេ បណ្តឹងឧទ្ធរណ៍នេះក៏មិនគួរនឹងទទួលយកដែរ ព្រោះថាៈ ទី១) ច្បាប់កំពុងអនុវត្ត និងបទដ្ឋានអន្តរជាតិ ដែលពាក់ព័ន្ធនឹងសិទ្ធិទទួលបាននូវការកាត់ក្តីដ៏ត្រឹមត្រូវ តម្រូវឲ្យមានការបកប្រែឯកសារជាក់លាក់តែមួយចំនួនប៉ុណ្ណោះ (មិនមែនទាំងអស់នោះទេ) ឲ្យទៅជាភាសាមួយដែលចុងចោទយល់បាន, ទី២) ចុងចោទមិនមានសិទ្ធិឲ្យគេបកប្រែគ្រប់ឯកសារទាំងអស់ ឲ្យទៅជាភាសារបស់ក្រុមមេធាវីអន្តរជាតិរបស់ខ្លួននោះទេ ជាពិសេស នៅពេលដែលក្រុមមេធាវីការពារក្តី និងផ្នែកគាំពារការពារក្តីមានសមត្ថភាពផ្នែកភាសាវិទ្យាគ្រប់គ្រាន់រួចទៅហើយនោះ, និងទី៣) បញ្ញត្តិស្តីពីអ្នកបកប្រែដោយមិនគិតកម្រៃ បន្ថែមឲ្យទៅខាងក្រុមមេធាវីការពារក្តីនោះ មិនបានបដិសេធសមភាពនៃអំណាច [រវាងការដាក់ និងដោះបន្ទុក] នោះទេ ក៏ប៉ុន្តែបានបន្ថែមទៅលើសមត្ថភាពផ្នែកភាសាវិទ្យារបស់ខ្លួនទៅវិញទេ ។

---

[4] *ករណីរបស់ អៀង សារី,* បណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងនឹងដីកាសម្រេចរបស់ ក.ស.ច.ស ស្តីពី សិទ្ធិ និងកាតព្វកិច្ចរបស់ភាគី ទាក់ទងនឹងការបកប្រែ, សំណុំរឿងព្រហ្មទណ្ឌលេខៈ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ-១២) ចុះថ្ងៃទី២២ កក្កដា ២០០៨, កថាខណ្ឌទី ៧-៨ [*បន្ទាប់ពីនេះទៅហៅថាៈ* បណ្តឹងឧទ្ធរណ៍] ។

[5] វិធាន ៧៤.៣ នៃវិធានផ្ទៃក្នុង [*បន្ទាប់ពីនេះទៅហៅថាៈ* វិធាន] ។

## ២. សំណើពីដំបូងៗ

*មិនតម្រូវឲ្យមានសវនាការផ្ទាល់មាត់ទេ*

៤. សហព្រះរាជអាជ្ញា ស្នើថា ពុំចាំបាច់មានសវនាការផ្ទាល់មាត់ទេ ព្រោះថា ភាគីនានាធ្លាប់បានដាក់សារណាស្តីពីអង្គហេតុ និងអង្គច្បាប់ពាក់ព័ន្ធនឹងបណ្តឹងឧទ្ធរណ៍នេះយ៉ាងគ្រប់គ្រាន់ជូនទៅអង្គបុរេជំនុំជម្រះរួចហើយ ។ អាស្រ័យហេតុនេះ សហព្រះរាជអាជ្ញា ស្នើឲ្យ អង្គបុរេជំនុំជម្រះ សម្រេចកំណត់បណ្តឹងឧទ្ធរណ៍នេះ ត្រឹមតែជាសេចក្តីសំអាងជាលាយលក្ខអក្សរប៉ុណ្ណោះបានហើយ ។ ភាគីប្តឹងឧទ្ធរណ៍ ក៏បានស្នើស្រដៀងគ្នានេះដែរ[6] ។ សេចក្តីណែនាំអនុវត្តសម្រាប់ការដាក់ឯកសារ ("សេចក្តីណែនាំអនុវត្ត") និងការអនុវត្តន៍របស់អង្គបុរេជំនុំជម្រះ លើករណីស្រដៀងគ្នានេះ បានអនុញ្ញាតឲ្យប្រើអំណាចបែបនេះបាន[7] ។

*ព័ត៌មានសាធារណៈ*

៥. សហព្រះរាជអាជ្ញា ស្នើឲ្យ អង្គបុរេជំនុំជម្រះ ដាក់ចម្លើយតបនេះតាមការគួរទៅក្នុងវិបសាយរបស់ អ.វ.ត.ក ទន្ទឹមគ្នានឹងការដាក់ជូនឯកសារនានាដែលពាក់ព័ន្ធនឹងបណ្តឹងឧទ្ធរណ៍នេះ ។ ការណ៍នេះគឺស្របទៅតាមវិធាន ៧៧.៦ នៃវិធានផ្ទៃក្នុង ដែលចែងថា អង្គបុរេជំនុំជម្រះ អាចសម្រេចថា នីតិវិធីទាំងស្រុង ឬមួយផ្នែកនៃសវនាការ (ហើយបើតាមការពិចារណា ទោះជាសេចក្តីសំអាង ឬជាសេចក្តីសម្រេចក៏ដោយ) ត្រូវធ្វើជាសាធារណៈ ។ ដើម្បីធ្វើដូច្នេះ អង្គបុរេជំនុំជម្រះ ត្រូវតែពិចារណាថា ការណ៍នេះដើម្បីជាប្រយោជន៍យុត្តិធម៌ និងមិនធ្វើឲ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ ឬវិធានការការពាររបស់តុលាការ[8] ។

---

[6] បណ្តឹងឧទ្ធរណ៍, ទំព័រទី៦ ។

[7] ការដាក់ឯកសារនៅចំពោះមុខ អ.វ.ត.ក, សេចក្តីណែនាំអនុវត្ត 01/2007/Rev.1 ចុះថ្ងៃទី០៥ តុលា ២០០៧, មាត្រា ៨.៤ ។ *ករណីរបស់ អៀង សារី,* សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ពាក់ព័ន្ធទៅនឹងការប្រាស្រ័យទាក់ទងគ្នារវាងជនត្រូវចោទនឹងប្រពន្ធរបស់គាត់, សំណុំរឿងលេខៈ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ-០៥) ចុះថ្ងៃទី៣០ មេសា ២០០៨, លេខERN 00184951-00184956, A104/II/7 កថាខណ្ឌទី ៨ ។

[8] វិធាន ៧៧.៦ នៃវិធានផ្ទៃក្នុង ។

៦. ការអនុវត្តន៍របស់ អង្គបុរេជំនុំជម្រះ បានឆ្លុះបញ្ចាំងស្របតាមស្មារតីនៃមាត្រានេះ នៅក្នុងសវនាការសាធារណៈរបស់ខ្លួន ការស្វែងរកជំនួយពីសំណាក់មិត្តរបស់តុលាការ (amici curiae) ការកាត់សេចក្តីជាសាធារណៈ ព្រមទាំងនៅក្នុងការដាក់សេចក្តីសំអាងហេតុរបស់ភាគីនានា និងសេចក្តីសម្រេចទាំងឡាយចូលទៅក្នុងវិបសាយរបស់ អ.វ.ត.ក ។

## ៣. ប្រវត្តិដំណើរការនីតិវិធីដែលពាក់ព័ន្ធ

៧. នៅថ្ងៃទី១០ ខែមករា ឆ្នាំ២០០៨ ដោយទាមទារថា "រាល់បំណងក្នុងការជួយដល់ក្រុមមេធាវីការពារក្តីក្នុងការត្រៀមរៀបចំការការពារក្តីរបស់ខ្លួន" ភាគីប្តឹងឧទ្ធរណ៍ បានសុំ សហចៅក្រមស៊ើបអង្កេត ឲ្យមានការបកប្រែ"រាល់ឯកសារគាំទ្រ"ទាំងអស់ដែលចំណុះនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររបស់ សហព្រះរាជអាជ្ញា ទៅជាភាសាខ្មែរ[9] ។ នៅថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០០៨ គឺនៅក្រោយសំណើរបស់ខ្លួនកាលពីថ្ងៃទី១០ ខែមករា ឆ្នាំ២០០៨ ភាគីប្តឹងឧទ្ធរណ៍ "ក៏បានស្នើសុំឲ្យមានការបកប្រែរាល់ឯកសារដែលបានលើកឡើងខាងលើ ឲ្យទៅជាភាសាអង់គ្លេស"[10] ។ ជនត្រូវចោទផ្សេងៗទៀត ក៏បានធ្វើសំណើទៅ សហចៅក្រមស៊ើបអង្កេត ឲ្យមានការបកប្រែឯកសារជាក់លាក់មួយចំនួន ដែលមាននៅក្នុងសំណុំរឿង ផងដែរ[11] ។

៨. គ្រានោះ នៅថ្ងៃទី២៣ ខែមេសា ឆ្នាំ២០០៨ ក្នុងអំឡុងពេលសវនាការលើបណ្តឹងឧទ្ធរណ៍ជំទាស់ទៅនឹងការឃុំខ្លួនបណ្តោះអាសន្នរបស់សហជនត្រូវចោទឈ្មោះ ខៀវ សំផន មេធាវីការពារក្តីអន្តរជាតិរបស់គាត់ បានស្វែងរកការពន្យារពេលនៃដំណើរការនីតិវិធីដោយគ្មាន

---

[9] *ករណីរបស់ អៀង សារី,* សំណើសុំពន្លឿនការបកប្រែរាល់ឯកសារចំណុះនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ, សំណុំរឿងព្រហ្មទណ្ឌលេខៈ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស ចុះថ្ងៃទី១០ មករា ២០០៨, លេខERN 00157754-00157756, A120 ។

[10] *ករណីរបស់ អៀង សារី,* កង្វះការឆ្លើយតបទៅនឹងសំណើសុំពន្លឿនការបកប្រែរាល់ឯកសារចំណុះនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ទៅជាភាសាខ្មែរ និងអង់គ្លេស, សំណុំរឿងព្រហ្មទណ្ឌលេខៈ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស ចុះថ្ងៃទី០៦ ឧសភា ២០០៨, លេខERN 00186401-00186403, A120/I ។

[11] សេចក្តីសម្រេចទាក់ទងនឹងការបកប្រែ, ទំព័រទី ២ ។

កំណត់រហូតទាល់តែឯកសារទាំងអស់នៅក្នុង សំណុំរឿងត្រូវបានបកប្រែទៅជាភាសារបស់ក្រុមមេធាវីការពារក្តី គឺភាសាបារាំង[12] ។ នៅពេលធ្វើការពន្យារពេលសវនាការ អង្គបុរេជំនុំជម្រះ បានកត់សម្គាល់ថា ការបដិសេធរបស់ក្រុមមេធាវីអន្តរជាតិមិនព្រមធ្វើសកម្មភាពបន្តគឺជាការដកថយពីបណ្តឹងឧទ្ធរណ៍តាមគតិច្បាប់ ហើយមានអនុភាពដោយចំពោះផង និងអនុភាពជំទាស់នឹងសិទ្ធិជាមូលដ្ឋានរបស់ ខៀវ សំផន ក្នុងការមានអ្នកតំណាងផង[13] ។ អង្គបុរេជំនុំជម្រះ បានកត់សម្គាល់ថា វិធានផ្ទៃក្នុងបានទទួលស្គាល់ពីសេចក្តីត្រូវការនៃសហប្រតិបត្តិការរវាងក្រុមមេធាវីជាតិ និងអន្តរជាតិ ។ អង្គបុរេជំនុំជម្រះ បានកត់សម្គាល់ថា វិធាន ២១.១ នៃវិធានផ្ទៃក្នុង បានណែនាំឲ្យមានសហប្រតិបត្តិការនេះយ៉ាងមានប្រសិទ្ធិភាព ដោយតម្រូវឲ្យក្រុមមេធាវីការពារក្តីលើកឡើងពីបញ្ហាទាំងស្រុងផ្នែកភាសាវិទ្យានេះ។ អង្គបុរេជំនុំជម្រះ បានសង្កេតឃើញថា អវត្តមាននៃសហប្រតិបត្តិការនេះ នាំឲ្យចុងចោទមានជម្រើសមួយដើម្បីជ្រើសរើសមេធាវីការពារក្តីថ្មីមួយឲ្យធ្វើជាអ្នកតំណាងរបស់គាត់[14]។

៩. នៅថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៨ សហចៅក្រមស៊ើបអង្កេត បានចេញសេចក្តីសម្រេចរបស់ខ្លួនមួយទាក់ទងនឹងការបកប្រែ ដើម្បីស្វែងរកសេចក្តីសម្រេចលើសំណើសុំឲ្យមានការបកប្រែទាំងឡាយដែលនៅមិនទាន់បានឆ្លើយតប ។ សេចក្តីសម្រេចទាក់ទងនឹងការបកប្រែ បានកត់សម្គាល់ថា កង្វះខាតនៅក្នុងបញ្ញត្តិច្បាប់ពាក់ព័ន្ធនឹងសិទ្ធិនៃការបកប្រែ និងបានដោះស្រាយបញ្ហាសិទ្ធិរបស់ចុងចោទទាក់ទងនឹងការបកប្រែ ក្នុងដំណាក់កាលនៃការជំនុំជម្រះមុនអង្គហេតុ នៅពេលដែលសហចៅក្រមស៊ើបអង្កេតជាប់រវល់ក្នុងដំណើរការស៊ើបសួរ ។ សេចក្តីសម្រេចនោះ បានកត់សម្គាល់ថាអង្គបុរេជំនុំជម្រះ និងអង្គជំនុំជម្រះសាលាដំបូង

---

[12] *ករណីរបស់ ខៀវ សំផន,* សេចក្តីសម្រេចលើសំណើសុំពន្យារពេលសវនាការលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាឃុំខ្លួនបណ្តោះអាសន្ន, សំណុំរឿងព្រហ្មទណ្ឌលេខ៖ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ-០៤) ចុះថ្ងៃទី២៣ មេសា ២០០៨, លេខERN 00180341-00180344, C26/I/25 កថាខណ្ឌទី ២ [*បន្ទាប់ពីនេះទៅហៅថា៖* សេចក្តីសម្រេចលើសំណើសុំពន្យារពេលសវនាការរបស់ ខៀវ សំផន] ។

[13] សេចក្តីសម្រេចលើសំណើសុំពន្យារពេលសវនាការរបស់ ខៀវ សំផន, កថាខណ្ឌទី ៩ ។

[14] សេចក្តីសម្រេចលើសំណើសុំពន្យារពេលសវនាការរបស់ ខៀវ សំផន, កថាខណ្ឌទី ១២ ។

00212462



អាចនឹងចេញដីកាសម្រេចបែបនេះបន្ថែមទៀត តាមដែលផលប្រយោជន៍យុត្តិធម៌ និងសិទ្ធិក្នុងការទទួលបាននូវការកាត់ក្តីដ៏ត្រឹមត្រូវ អាចនឹងតម្រូវឲ្យធ្វើ[15] ។

១០. ក្នុងចំណោមនោះ សេចក្តីសម្រេចទាក់ទងនឹងការបកប្រែ បានចែងថាចុងចោទមានសិទ្ធិដើម្បីទទួលបាននូវភាសាមួយដែលខ្លួនយល់បាន (ភាសាខ្មែរ) លើឯកសារទាំងឡាយដូចតទៅនេះ ៖ ទី១) ដីកាបញ្ជូនរឿងទៅជំនុំជម្រះ តាមវិធាន ៦៧.១, ទី២) ធាតុផ្សំនានានៃភស្តុតាង ដែលជាមូលដ្ឋាននៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ, និងទី៣) ដីកាសន្និដ្ឋានបញ្ជូនរឿងទៅជំនុំជម្រះ និងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា ហើយកំណត់សម្គាល់ជើងទំព័រ និងលិបិក្រមនៃធាតុផ្សំអង្គហេតុ ដែលជាមូលដ្ឋាននៃដីកាទាំងនោះ។ សេចក្តីសម្រេចនោះ បានកត់សម្គាល់ថាសេចក្តីសម្រេចទាំងឡាយរបស់ចៅក្រម និងការដាក់ឯកសាររបស់ភាគីនានា នឹងត្រូវបានផ្តល់ជូនបន្តទៀតជាភាសាខ្មែរ និងយ៉ាងហោចណាស់ជាភាសាមួយផ្សេងទៀតតាមជម្រើសរបស់ចុងចោទ ដូចដែលសេចក្តីណែនាំអនុវត្តបានតម្រូវឲ្យធ្វើ[16] ។

១១. សេចក្តីសម្រេចទាក់ទងនឹងការបកប្រែ បានតម្រូវឲ្យភាគីនានាដោះស្រាយសេចក្តីត្រូវការបកប្រែ ដោយប្រើសមត្ថភាពផ្នែកភាសាវិទ្យានៅក្នុងក្រុមរបស់ខ្លួន និងពីខាងអង្គភាពគាំពារការការពារក្តី[17] ។ តាមការរៀបរាប់អំពីរបបគ្រប់គ្រងការបកប្រែបែបជឿនលឿនមួយ សេចក្តីសម្រេចនោះ បានសុំឲ្យភាគីនានាកាត់បន្ថយសេចក្តីត្រូវការបកប្រែ តាមរយៈការធ្វើឲ្យសមត្ថភាពផ្នែកភាសាវិទ្យារបស់ខ្លួនបានប្រសើរឡើង វាយតម្លៃនិងបញ្ជូនអាទិភាពទាំងនោះឲ្យទៅផ្នែកគ្រប់គ្រងតុលាការ ព្រមទាំងធ្វើសហប្រតិបត្តិការជាមួយនឹងផ្នែកគ្រប់គ្រងតុលាការ ដើម្បីឆ្ពោះទៅរកការយល់ស្របគ្នាមួយតាមដែលការគ្រប់គ្រងលើអាទិភាពទាំងនោះបានតម្រូវឲ្យធ្វើ[18] ។ ដើម្បីឲ្យដំណើការនៃសហប្រតិបត្តិការនេះ "ជាក់ស្តែង និងមាន

---

[15] សេចក្តីសម្រេចទាក់ទងនឹងការបកប្រែ, កថាខណ្ឌ E4 ។

[16] សេចក្តីសម្រេចទាក់ទងនឹងការបកប្រែ, កថាខណ្ឌ C3 ។

[17] សេចក្តីសម្រេចទាក់ទងនឹងការបកប្រែ, កថាខណ្ឌ A4 ។

[18] សេចក្តីសម្រេចទាក់ទងនឹងការបកប្រែ, កថាខណ្ឌ E2 ។

00212463

A190/II/5



ប្រសិទ្ធិភាព” សេចក្តីសម្រេចនោះបានចែងថា ក្រុមមេធាវីការពារក្តីនីមួយៗមានសិទ្ធិទទួលបាននូវអ្នកបកប្រែដោយមិនគិតកម្រៃម្នាក់ពីការិយាល័យរដ្ឋបាល[19] ។

១២. ដោយមិនសុខចិត្តនឹងសេចក្តីសម្រេចទាក់ទងនឹងការបកប្រែ ភាគីប្តឹងឧទ្ធរណ៍បានសម្រេចដាក់បណ្តឹងឧទ្ធរណ៍នេះ ។ ដូចដែលបានកត់សម្គាល់ខាងលើស្រាប់ ភាគីប្តឹងឧទ្ធរណ៍ អះអាងថា សេចក្តីសម្រេចនោះ៖ ទី១) បំពានលើសិទ្ធិចូលរួមនៅក្នុងការការពារក្តីរបស់គាត់ ដោយមិនបានផ្តល់ដល់រូបគាត់នូវគ្រប់ឯកសារទាំងអស់ជាភាសាខ្មែរ ដែលត្រូវដាក់នៅក្នុងសំណុំរឿង, ទី២) បំពានលើសិទ្ធិមានអ្នកតំណាងផ្នែកច្បាប់ការពារក្តីរបស់គាត់ ដោយមិនបានផ្តល់ដល់រូបគាត់នូវឯកសារទាំងនោះជាភាសាអង់គ្លេស ដែលជាភាសារបស់ក្រុមមេធាវីការពារក្តីអន្តរជាតិរបស់គាត់, និង ទី៣) បំពានលើសមភាពនៃអំណាច [រវាងការដាក់ និងដោះបន្ទុក] ដោយបំបែរបន្ទុកនៃការបកប្រែ ពីសមត្ថកិច្ចតុលាការនេះឲ្យទៅខាងអង្គភាពគាំពារការការពារក្តីទៅវិញ[20] ។

## ៤. អំពីច្បាប់

*សិទ្ធិរបស់ចុងចោទ ទាក់ទងនឹងការបកប្រែឯកសារឲ្យទៅជាភាសារបស់ខ្លួន គឺមានកំរិត*

១៣. ច្បាប់ និងវិធានផ្ទៃក្នុងសម្រាប់ អ.វ.ត.ក មិនបញ្ជាក់ឲ្យបានច្បាស់លាស់អំពីការបកប្រែឯកសារសម្រាប់ចុងចោទទេ ប៉ុន្តែច្បាប់ និងវិធានផ្ទៃក្នុងពិតជាបានចែងអំពី “ការប្រើប្រាស់អ្នកបកប្រែ”[21] ។ សេចក្តីណែនាំអនុវត្ត ចែងអំពីការដាក់ឯកសារជាភាសាខ្មែរ (ជាភាសាដែលគ្រប់ជនត្រូវចោទទាំងអស់ពេលបច្ចុប្បន្ននេះយល់បាន) បន្ថែមដោយភាសាផ្លូវការមួយផ្សេងទៀត[22] ។ ដូចគ្នានេះដែរ ឯកសារមូលដ្ឋានរបស់តុលាការអន្តរជាតិស្រដៀងគ្នាផ្សេងៗ

---

[19] សេចក្តីសម្រេចទាក់ទងនឹងការបកប្រែ, កថាខណ្ឌ E3 ។

[20] បណ្តឹងឧទ្ធរណ៍, កថាខណ្ឌទី ៧-៨ ។

[21] ច្បាប់ អ.វ.ត.ក, មាត្រា ៣៥.ច ។ វិធាន ៣០ នៃវិធានផ្ទៃក្នុង ។

[22] សេចក្តីណែនាំអនុវត្ត, មាត្រា ៧.១ និង ៧.២ ។

ទៀត ក៏មិនបានពណ៌នាឲ្យបានច្បាស់លាស់ពីវិសាលភាពនៃសិទ្ធិរបស់ចុងចោទ ទាក់ទងនឹងការបកប្រែដែរ ។ តុលាការព្រហ្មទណ្ឌអន្តរជាតិ (“ICC”) បានបញ្ញត្តប្រកាសមួយយ៉ាងច្បាស់លាស់ជាទីបំផុតអំពីសិទ្ធិរបស់ចុងចោទ ទាក់ទងនឹងការបកប្រែ និងធានាអំពីជំនួយពីសំណាក់អ្នកបកប្រែដោយមិនគិតកម្រៃ ហើយការបកប្រែទាំងនេះ គឺចាំបាច់ត្រូវតែត្រូវទៅតាមលក្ខខណ្ឌតម្រូវនៃយុត្តិធម៌ បើសិនជាមានដំណើរការនីតិវិធី ឬឯកសារណាមួយនៅក្នុងតុលាការមិនមានជាភាសាមួយដែលចុងចោទយល់ ឬនិយាយមិនបានទាំងស្រុង[23] ។ តុលាការសិទ្ធិមនុស្សអឺរ៉ុប (“ECHR”) បានតម្រូវឲ្យមានការបកប្រែផ្ទាល់មាត់ ឬបកប្រែសរសេរនូវគ្រប់ឯកសារទាំងអស់ ដែលចាំបាច់សម្រាប់ចុងចោទយល់បាន ដើម្បីជាប្រយោជន៍ដល់ការកាត់ក្តីដ៏ត្រឹមត្រូវមួយ[24] ។ តុលាការដទៃទៀត បានសម្រេចអំពីសិទ្ធិទាក់ទងនឹងការបកប្រែផ្ទាល់មាត់ ដើម្បីគ្របដណ្តប់លើសិទ្ធិទាក់ទងនឹងការបកប្រែសរសេរ នូវឯកសងារជាក់លាក់មួយចំនួន[25] ។

១៤. អង្គការយុត្តិធម៌អន្តរជាតិនានា បានមើលឃើញសិទ្ធិទាក់ទងនឹងការបកប្រែ តាមមធ្យោបាយបីយ៉ាងធំៗ ។ គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ (“HRC”) បានមើលឃើញសិទ្ធិទាំងនោះ ពីខាងទស្សនៈនៃការផ្តល់វត្ថុឬកាលៈទេសៈ ដែលជួយឲ្យបានងាយស្រួល

---

[23] លក្ខន្តិកៈទីក្រុងរ៉ូមសម្រាប់តុលាការព្រហ្មទណ្ឌអន្តរជាតិ, មាត្រា ៥១.១.គ, ៦៧.១.ច [*បន្ទាប់ពីនេះទៅហៅថា៖* លក្ខន្តិកៈទីក្រុងរ៉ូម]។ តុលាការព្រហ្មទណ្ឌអន្តរជាតិ, វិធាននៃនីតិវិធី និងភស្តុតាង, វិធាន ៤២ ៧៦.៣ ១៨៧ ២០៣ [*បន្ទាប់ពីនេះទៅហៅថា៖* វិធានសម្រាប់តុលាការ ICC] ។

[24] *Leudicke ទល់នឹង ប្រទេសអាល្លឺម៉ង់,* ពាក្យសុំលេខ ៦២១០/៧៣ ៦៨៧៧/៧៥ ៧១៣២/៧៥, សេចក្តីសម្រេច ចុះថ្ងៃទី២៨ វិច្ឆិកា ១៩៧៨, កថាខណ្ឌទី ៤៨ ។ *Kamasinski ទល់នឹង ប្រទេសអូទ្រីស,* ពាក្យសុំលេខ ៩៧៨៣/៨២, សេចក្តីសម្រេច ចុះថ្ងៃទី១៩ ធ្នូ ១៩៨៩, កថាខណ្ឌទី ៤៨ [*បន្ទាប់ពីនេះទៅហៅថា៖* សេចក្តីសម្រេចលើករណីរបស់ Leudicke]។

[25] លក្ខន្តិកៈសម្រាប់តុលាការ ICTR, មាត្រា ២០.៤.ច ។ ECHR, មាត្រា ៦.៣.ង ។ ច្បាប់ អ.វ.ត.ក, មាត្រា ៣៥.ច ។ *រដ្ឋអាជ្ញា ទល់នឹង Muhimana,* សំណុំរឿងលេខ ICTR-95-I-B-I, សេចក្តីសម្រេចលើញត្តិស្នើសុំរបស់មេធាវីការពារក្តី ស្តីពីការបកប្រែឯកសារដាក់បន្ទុក និងឯកសារនីតិវិធី ទៅជាភាសា Kinyarwanda, ចុះថ្ងៃទី០៦ វិច្ឆិកា ២០០១, កថាខណ្ឌទី ១៦ [*បន្ទាប់ពីនេះទៅហៅថា៖* សេចក្តីសម្រេចលើករណីរបស់ Muhimana]។ សេចក្តីសម្រេចលើករណីរបស់ Leudicke ។ កថាខណ្ឌទី ៧៤ ។

សម្រាប់ការត្រៀមរៀបចំកិច្ចការពារក្តី[26] ។ តុលាការ*ពិសេស (ad hoc tribunals)* បានមើលឃើញសិទ្ធិទាំងនោះថាជា តុល្យភាពមួយរវាងផលប្រយោជន៍របស់ចុងចោទក្នុងការទទួលបាននូវឯកសារ ដែលបានបកប្រែរួចស្រេច ហើយសិទ្ធិរបស់គាត់នឹងត្រូវបានធ្វើការជំនុំជម្រះដោយគ្មានការពន្យារពេលមិនសមហេតុផលឡើយ ដោយសារយល់ឃើញថាសេចក្តីត្រូវការបកប្រែមានកាន់តែច្រើនឡើងនោះ ល្បឿននៃដំណើរការនិតិវិធីក៏កាន់តែយឺតទៅៗដែរ[27]។ តុលាការ ICC និង ECHR បានសម្រេចថា គេត្រូវតែផ្តល់នូវការបកប្រែបែបដូច្នោះ ដើម្បី "ធានាដល់ចុងចោទឱ្យបានយល់ដឹងពីករណីប្រឆាំងនឹងរូបខ្លួន ហើយដើម្បីការពារខ្លួនគាត់ ជាសំខាន់គឺលទ្ធភាពក្នុងការឆ្លើយតបនៅចំពោះមុខតុលាការអំពីព្រឹត្តិការណ៍នានា ដោយសំដីផ្ទាល់របស់គាត់"[28] ។

១៥. សិទ្ធិរបស់ចុងចោទទាក់ទងនឹងការបកប្រែ មិនពន្លាតទៅដល់គ្រប់ឯកសារទាំងអស់ ដែលមាននៅក្នុងសំណុំរឿងទេ[29] ។ តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីត ប្រទេសយូហ្គោស្លាវី

---

[26] *Harward ទល់នឹង ប្រទេសន័រវេ,* សេចក្តីប្រកាសលេខ ៤៥១/១៩៩១, ឯកសាររបស់ អ.ស.ប CCPR/C51/D/451/1991, កថាខណ្ឌទី ៩.៤ (គណៈកម្មាធិការសិទ្ធិមនុស្ស ចុះថ្ងៃទី១៦ សីហា ១៩៩៤) [*បន្ទាប់ពីនេះទៅហៅថា៖* សេចក្តីសម្រេចលើករណីរបស់ Harward]។

[27] *រដ្ឋអាជ្ញា ទល់នឹង Seselj,* សំណុំរឿងលេខ IT-03-67-PT, សេចក្តីសម្រេចស្តីពីការបកប្រែ, ១ (អង្គជំនុំជម្រះសាលាដំបូង ទីII, ថ្ងៃទី០៦ មីនា ២០០៣) [*បន្ទាប់ពីនេះទៅហៅថា៖* សេចក្តីសម្រេចលើករណីរបស់ Seselj] ។ សេចក្តីសម្រេចលើករណីរបស់ Muhimana, កថាខណ្ឌទី ១២ ។ *រដ្ឋអាជ្ញា ទល់នឹង Ljubicic,* សំណុំរឿងលេខ IT-00-41-PT, សេចក្តីសម្រេចលើសំណើរបស់ក្រុមមេធាវីការពារក្តីស្តីពីការបកប្រែគ្រប់ឯកសារទាំងអស់, ៣ (អង្គជំនុំជម្រះសាលាដំបូង ទី I, ថ្ងៃទី២០ វិច្ឆិកា ២០០២) [*បន្ទាប់ពីនេះទៅហៅថា៖* សេចក្តីសម្រេចលើករណីរបស់ Ljubicic] ។

[28] *រដ្ឋអាជ្ញា ទល់នឹង Lubanga,* សំណុំរឿងលេខ ICC-01/04-01/06, សេចក្តីសម្រេចលើសំណើរបស់មេធាវីការពារក្តី ចុះថ្ងៃទី០៣ និង ០៤ កក្កដា ២០០៦ (អង្គបុរេជំនុំជម្រះ ទីI, ថ្ងៃទី០៤ សីហា ២០០៦) [*បន្ទាប់ពីនេះទៅហៅថា៖* សេចក្តីសម្រេចលើករណីរបស់ Lubanga] ។

[29] សេចក្តីសម្រេចលើករណីរបស់ Harward, កថាខណ្ឌទី ៩.៥ ។ *រដ្ឋអាជ្ញា ទល់នឹង Katanga,* សំណុំរឿងលេខ ICC-01/04-01/07, សេចក្តីសម្រេចលើសំណើរបស់មេធាវីការពារក្តីរបស់ Mathieu Ngudjolo Chui ពាក់ព័ន្ធនឹងការបកប្រែឯកសារ ៣, ៥ (អង្គបុរេជំនុំជម្រះ ទីI, ថ្ងៃទី១៥ ឧសភា ២០០៨) [*បន្ទាប់ពីនេះទៅហៅថា៖* សេចក្តីសម្រេចលើករណីរបស់ Katanga] ។ *រដ្ឋអាជ្ញា ទល់នឹង Chui,* សំណុំរឿងលេខ ICC-01/04-02/07, សេចក្តីសម្រេចលើសំណើរបស់មេធាវីការពារក្តី ពាក់ព័ន្ធនឹងការកំណត់ពេល ៤ (អង្គបុរេជំនុំជម្រះ ទីI, ថ្ងៃទី២៧ កុម្ភៈ ២០០៨) [*បន្ទាប់ពីនេះទៅហៅថា៖* សេចក្តីសម្រេចលើករណីរបស់ Chui] ។ សេចក្តីសម្រេចលើករណីរបស់ Muhimana, កថាខណ្ឌទី ២៥ ។

(“ICTY”) និងប្រទេសរ្វាន់ដា(“ICTR”) បានបដិសេធសំណើសុំឲ្យមានការបកប្រែគ្រប់ឯកសារទាំងអស់ ដោយផ្អែកលើមូលដ្ឋានមួយថា ការបកប្រែឯកសារជាមុនឲ្យទៅជាភាសារបស់ចុងចោទដែលហួសពីតម្រូវការនោះ នឹងនាំឲ្យអន្តរាយយ៉ាងធ្ងន់ធ្ងរដល់សិទ្ធិរបស់ចុងចោទក្នុងការទទួលបាននូវការកាត់ក្តីមួយដ៏ឆាប់រហ័ស ព្រោះថាគេមុខជានឹងត្រូវការពេលវេលា និងធនធានយ៉ាងច្រើន[30] ។ តុលាការ ICC បានសម្រេចថាគោលការណ៍ យុត្តិធម៌មិនធានាដល់ចុងចោទពីសិទ្ធិទទួលបានគ្រប់ឯកសារទាំងអស់តាមដំណើរការនីតិវិធី និងឯកសារជាភស្តុតាងទាំងអស់ទេ[31] ។ តុលាការ ICTY បានបដិសេធ សូម្បីតែការបកប្រែគ្រប់ឯកសារទាំងអស់ដែលជាការការពារខ្លួនដោយចុងចោទខ្លួនឯងក៏ដោយ[32] ។

១៦. ការផ្តល់ឲ្យចុងចោទនូវអ្នកបកប្រែផ្ទាល់មាត់ម្នាក់ គឺជាការជំនួសដ៏គ្រប់គ្រាន់មួយ សំរាប់ការផ្តល់ជូននូវឯកសារជាក់លាក់នានា តាមភាសាដែលគាត់យល់បាន[33] ។ តុលាការ ICTY និយាយថាប្រសិនបើអ្នកគ្រប់គ្រងបញ្ជីរបស់ខ្លួនរកឃើញថាមានការលំបាកនៅក្នុងការបកប្រែសរសេរនូវឯកសារជាក់លាក់មួយចំនួនទៅជាភាសារបស់ចុងចោទ នោះអ្នកគ្រប់គ្រងបញ្ជីអាចធ្វើការបកប្រែផ្ទាល់មាត់ទៅលើឯកសារទាំងនោះ “ដើម្បីឲ្យ [ចុងចោទ] មានលទ្ធភាពទទួលបាននូវចំណុចសំខាន់ៗនៃខ្លឹមសាររបស់វា”[34] ។ តុលាការ ICC ផ្តល់ឲ្យចុងចោទនូវអ្នកបកប្រែផ្ទាល់មាត់ម្នាក់ ជំនួសការផ្តល់ឲ្យចុងចោទនូវការបកប្រែសរសេរនូវឯកសារនានាហួសពីអ្វីដែលបានតម្រូវដោយលិខិតុបករណ៍របស់ខ្លួន ។

[30] សេចក្តីសម្រេចលើករណីរបស់ Seselj, ទំព័រទី ១ ។ សេចក្តីសម្រេចលើករណីរបស់ Muhimana, កថាខណ្ឌទី ១២ ។

[31] សេចក្តីសម្រេចលើករណីរបស់ Lubanga, ទំព័រទី ៥-៦ ។ សេចក្តីសម្រេចលើករណីរបស់ Katanga, ទំព័រទី ៦ ។

[32] សេចក្តីសម្រេចលើករណីរបស់ Seselj, ទំព័រទី ១ ។

[33] សេចក្តីសម្រេចលើករណី Harward, កថាខណ្ឌទី ៩.៥ ។

[34] សេចក្តីសម្រេចលើករណី Muhimana, កថាខណ្ឌទី ៣០ ។

*តើឯកសារប្រភេទអ្វីខ្លះដែលតម្រូវឲ្យមានការបកប្រែទៅជាភាសារបស់ចុងចោទ?*

១៧. វិធាន ៦៧ តម្រូវថា ចុងចោទត្រូវទទួលបានជាបន្ទាន់នូវដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) មួយច្បាប់ដែលត្រូវផ្តល់ជូនដោយសហចៅក្រមស៊ើបអង្កេត ។ ទោះជាយ៉ាងដូច្នេះក៏ដោយ បញ្ញត្តិនេះមិនបានបញ្ជាក់ឲ្យបានច្បាស់លាស់អំពីការផ្តល់ដល់ចុងចោទ នូវសិទ្ធិទទួលបានដីកាបញ្ជូនរឿងទៅជំនុំជម្រះតាមភាសាមួយដែលគាត់យល់បាននោះទេ ។ តុលាការអន្តរជាតិដែលសឹងតែគ្មានការលើកលែងអ្វីទាំងអស់ ផ្តល់ឲ្យចុងចោទរបស់ខ្លួននូវដីកាបញ្ជូនរឿងទៅជំនុំជម្រះជាភាសាមួយដែលគេយល់បាន ទោះបីជាយុត្តិសាស្ត្រស្តីពីការបកប្រែឯកសារគាំទ្រចំពោះដីកាបញ្ជូនរឿងទៅជំនុំជម្រះមិនស៊ីសង្វាក់គ្នាក៏ដោយ[35]។ តុលាការ ICTY និង ICTR ផ្តល់នូវឯកសារដូចនេះជាភាសារបស់ចុងចោទ គឺដោយសារតែបញ្ហាសិទ្ធិ[36]។ សិទ្ធិនេះអនុវត្តចំពោះគ្រប់ឯកសារគាំទ្រទាំងអស់ ដោយមិនគិតថាតើឯកសារនោះបានបង្ហាញនៅក្នុងពេលជំនុំជម្រះនោះឡើយ[37] ។ ទោះជាយ៉ាងដូច្នេះក៏ដោយ តុលាការ ICC ផ្តល់ឲ្យមានការបកប្រែឲ្យទៅជាភាសារបស់ចុងចោទ តែបញ្ជីភស្តុតាងដែលគាំទ្រចំពោះដីកាបញ្ជូនរឿងទៅជំនុំជម្រះប៉ុណ្ណោះ។ នៅក្នុងករណីរបស់ *Lubanga,* តុលាការ ICC បានសម្រេចថា ការបកប្រែសេចក្តីរៀបរាប់ពិស្តារនៃបទចោទ ជាមួយនឹងបញ្ជីភស្តុតាង គឺជាការជូនដំណឹងដល់ចុងចោទយ៉ាងគ្រប់គ្រាន់ហើយ អំពីប្រភេទ បុព្វហេតុ និងខ្លឹមសារនៃបទចោទប្រឆាំងនឹងជននោះ[38] ។ តុលាការ ICC បានច្រានចោលពាក្យសុំរបស់ចុងចោទ ដែលស្នើសុំឯកសារគាំទ្រដីកាបញ្ជូនរឿងទៅជំនុំជម្រះជាភាសារបស់ខ្លួន ប៉ុន្តែបានជំនួសមកវិញដោយបានផ្តល់ឲ្យគាត់នូវការប្រើប្រាស់អ្នកបកប្រែផ្ទាល់មាត់ម្នាក់ជាអចិន្ត្រៃយ៍[39] ។

[35] វិធាន ៤៧.ឆ នៃវិធានសម្រាប់តុលាការ ICTY ។ វិធាន ៤៧.ឆ នៃវិធានសម្រាប់តុលាការ ICTR ។

[36] វិធាន ៦៦.ក នៃវិធានសម្រាប់តុលាការ ICTY ។ វិធាន ៦៦.ក នៃវិធានសម្រាប់តុលាការ ICTR ។

[37] សេចក្តីសម្រេចលើករណីរបស់ Seselj, ទំព័រទី ១ ។ សេចក្តីសម្រេចករណីរបស់ Ljubicic, ទំព័រទី ៣ ។ សេចក្តីសម្រេចលើករណីរបស់ Muhimana, កថាខណ្ឌទី ២៣ ។

[38] វិធាន ១២១.៣ នៃវិធានសម្រាប់តុលាការ ICC ។

[39] សេចក្តីសម្រេចលើករណីរបស់ Lubanga, ទំព័រទី ៧ ។

១៨. ជាការបន្ថែមចំពោះដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងឯកសារគាំទ្ររបស់ដីកានេះ តុលាការបាន បានសម្រេចថា វត្ថុតាងឯកសារផ្សេងៗខុសៗគ្នា ត្រូវតែដាក់បង្ហាញដល់ចុងចោទតាមភាសារបស់គេ ។ សេចក្តីរៀបរាប់នៃឯកសារទាំងអស់នេះ គឺខុសៗគ្នា ។ ជាពិសេស តុលាការអន្តរ-ជាតិ*ពិសេស* បានតម្រូវថា ឯកសារផ្សេងៗដែលបានបង្ហាញដូចតទៅនេះត្រូវតែបកប្រែទៅជាភាសាដែលចុងចោទយល់បាន៖ ទី១) កំណត់ហេតុសាក្សីដែលអយ្យការមានបំណងយកមកបង្ហាញនៅក្នុងសវនាការជំនុំជម្រះក្តី[40], ទី២) ភស្តុតាងនានាដែលនឹងត្រូវយកមកបង្ហាញនៅក្នុងការជំនុំជម្រះក្តី[41], ទី៣) ភស្តុតាងដោះបន្ទុកស្ថិតនៅក្រោមការកាន់កាប់ និងចំណេះដឹងរបស់អយ្យការ[42] ។ តុលាការ ICTY បានកំណត់ថា ក្រៅអំពីភស្តុតាងគាំទ្រដីកាបញ្ជូនរឿងទៅជំនុំជម្រះ អយ្យការត្រូវបកប្រែឯកសារទាំងឡាយ ដែលបង្កើតបានជាទម្រង់មូលដ្ឋាននៃការកំណត់អំពីបទចោទប្រកាន់ប្រឆាំងនឹងចុងចោទ[43] ។ តុលាការបានផ្តល់យុត្តិកម្មសំរាប់ការដាក់កម្រិតនេះថា លិខិតុបករណ៍របស់ខ្លួនមិនផ្តល់សិទ្ធិដល់ចុងចោទត្រូវតែទទួលបានឯកសារ*ទាំងអស់* ជាភាសាដែលខ្លួនយល់នោះឡើយ ប៉ុន្តែមានតែឯកសារទាំងឡាយណាដែលកំណត់ពីពិរុទ្ធភាព និងភាពគ្មានទោសរបស់ចុងចោទនៅក្នុងពេលជំនុំជម្រះតែប៉ុណ្ណោះ[44] ។ ទោះជាយ៉ាងនេះក្តី តុលាការ ICC មិនព្រមផ្តល់នូវការបកប្រែលើភស្តុតាងសំរាប់ដោះបន្ទុកទេ[45] ។ តុលាការ ICC ក៏បានកំណត់ផងដែរថា អយ្យការមិនតម្រូវឲ្យបកប្រែគ្រប់ឯកសារទាំងអស់ដែលខ្លួនជាប់កាតព្វកិច្ចត្រូវដាក់បង្ហាញដល់មេធាវីការពារក្តីនោះទេ[46] ។ តុលាការនេះបានចង្អុលបង្ហាញថា វត្ថុតាងឯកសារដែលបានបញ្ជាក់យ៉ាងច្បាស់ ដែលអយ្យការត្រូវតែបកប្រែនោះ គឺកំណត់ហេតុសាក្សីដាក់បន្ទុកនានាតែប៉ុណ្ណោះ [47] ។

---

[40] សេចក្តីសម្រេចលើករណីរបស់ Muhimana, កថាខណ្ឌទី ២៣ ។ វិធាន ៦៦.ក.២ នៃវិធានសម្រាប់តុលាការ ICTY ។ សេចក្តីសម្រេចលើករណីរបស់ Seselj, ទំព័រទី ១ ។ សេចក្តីសម្រេចលើករណីរបស់ Ljubicic, ទំព័រទី ១ ។

[41] សេចក្តីសម្រេចលើករណីរបស់ Muhimana, កថាខណ្ឌទី ២៥ ។

[42] សេចក្តីសម្រេចលើករណីរបស់ Ljubicic, ទំព័រទី ៣ ។

[43] សេចក្តីសម្រេចលើករណីរបស់ Naletilic, ទំព័រទី ៣ ។

[44] សេចក្តីសម្រេចលើករណីរបស់ Delalic, កថាខណ្ឌទី ៨ ។

[45] សេចក្តីសម្រេចលើករណីរបស់ Lubanga, ទំព័រទី ៥-៨ ។

[46] សេចក្តីសម្រេចលើករណីរបស់ Lubanga, ទំព័រទី ៧ ។

[47] សេចក្តីសម្រេចលើករណីរបស់ Chui, ទំព័រទី ៤ (ដែលយោងដល់វិធានសម្រាប់តុលាការ ICC, វិធាន ៧៦.៣ ) ។

*តើអ្នកណាជាអ្នកត្រូវទទួលបន្ទុកនៃការបកប្រែឯកសារនានា?*

១៩. លិខិតុបករណ៍របស់អង្គជំនុំជម្រះនេះ មិនបានធ្វើប្រតិភូកម្មតួនាទីនៃការបកប្រែយ៉ាងច្បាស់លាស់ទៅឱ្យអង្គភាពជាក់លាក់ណាមួយទេ ។ សេចក្ដីណែនាំអនុវត្ត បានដាក់ការទទួលខុសត្រូវនៃការបកប្រែសេចក្ដីសំអាងជាក់លាក់នានា ទៅលើផ្នែកគ្រប់គ្រងតុលាការ[48] ប៉ុន្តែគ្មានការធ្វើប្រតិភូកម្មច្បាស់លាស់ ចំពោះការងារបកប្រែឯកសារប្រភេទផ្សេងៗទៀតទេ ជាពិសេសចំពោះឯកសារជាភស្តុតាង ។

២០. តុលាការ ICTR បានតម្រូវឱ្យអ្នកកាន់បញ្ជីរបស់ខ្លួន ធ្វើការបកប្រែឯកសារទាំងឡាយណាដែលគេបានរកឃើញថាចាំបាច់ត្រូវផ្ដល់ឱ្យចុងចោទ ជាភាសារបស់គេតែប៉ុណ្ណោះ[49] ។ ផ្ទុយមកវិញ នៅចំពោះមុខតុលាការ ICC លើកលែងតែឯកសារទាំងឡាយដែលបានដាក់លក្ខខណ្ឌតម្រូវដល់អយ្យការត្រូវផ្ដល់ឱ្យចុងចោទជាភាសារបស់គេ ក្រុមមេធាវីការពារក្ដីត្រូវទទួលខុសត្រូវរៀបចំធនធានរបស់ខ្លួនដើម្បីការពារសិទ្ធិរបស់ចុងចោទ[50] ។

*គ្មានសិទ្ធិបកប្រែឯកសារនានាទៅជាភាសារបស់មេធាវីការពារក្ដីទេ*

២១. សូម្បីលិខិតុបករណ៍របស់អង្គជំនុំជម្រះនេះ និងរបស់តុលាការអន្តរជាតិស្រដៀងគ្នាដទៃទៀត ក៏មិនមានបទប្បញ្ញត្តិច្បាស់លាស់ណាមួយ ដែលចែងអំពីសិទ្ធិរបស់ក្រុមមេធាវីការពារក្ដីទាក់ទងនឹងការបកប្រែឯកសារនោះដែរ ។

[48] សេចក្ដីណែនាំអនុវត្ត, មាត្រា ៧.២ ។

[49] សេចក្ដីសម្រេចលើករណីរបស់ Muhimana, កថាខណ្ឌទី ១០, ១៣ ។

[50] សេចក្ដីសម្រេចលើករណីរបស់ Chui, ទំព័រទី ៥ ។ សេចក្ដីសម្រេចលើករណីរបស់ Katanga, ទំព័រទី ៣, ៦ ។

២២. នៅក្នុងករណី *Muhimana,* តុលាការ ICTR បានធ្វើការពិចារណាថាតើក្រុមមេធាវីការពារក្តីដែលជាមនុស្សអភិរក្សភាសាបារាំង មានសិទ្ធិទទួលបានឯកសារទាំងអស់ដែលបានបង្ហាញដោយអយ្យការជាភាសាបារាំងដែរឬទេ និងដើម្បីឱ្យអ្នកកាន់បញ្ជីធានាលើការបកប្រែដោយសេរីលើគ្រប់ឯកសារជាលាយលក្ខណ៍អក្សរទាំងអស់ ។ តុលាការនេះបានតម្រូវថា ឯកសារចំនួនពីរប្រភេទគួរតែបានបកប្រែទៅជាភាសាផ្លូវការទាំងពីរ៖ ទី១) សារណារបស់គូភាគី និងទី២) ភស្តុតាងដែលយកជាសំអាងនៅពេលសវនាការជំនុំជម្រះ[51] ។ នៅក្នុងករណីនោះ សូម្បីមានតែមេធាវីការពារក្តីម្នាក់ នៅក្នុងចំណោមមេធាវីទាំងនោះចេះនិយាយ និងយល់បានតែភាសាបារាំងក៏ដោយ ក៏ប៉ុន្តែមេធាវីម្នាក់ផ្សេងទៀតចេះនិយាយ និងយល់បានភាសាបារាំង និងទាំងភាសាអង់គ្លេស[52] ។ តុលាការបានកំណត់ថា លទ្ធភាពក្នុងការបកប្រែរបស់ក្រុមមេធាវីការពារក្តីម្នាក់មិនបានជួយសម្រាលដល់កាតព្វកិច្ចរបស់តុលាការ ដើម្បីបកប្រែសេចក្តីសម្រេចសារណាជាលាយលក្ខណ៍អក្សរ និងភស្តុតាងនានាទេ[53] ។ យ៉ាងណាក៏ដោយ គេមានការសង្ឃឹមថា “តាមរយៈកិច្ចសហការប្រកបដោយផ្លែផ្កា” មេធាវីម្នាក់ អាចជួយមេធាវីម្នាក់ផ្សេងទៀត “ឱ្យយល់អំពីខ្លឹមសារនៃឯកសារនានាបាន”[54] ។

២៣. នៅក្នុងករណី *Lubanga,* ចុងចោទបានស្នើសុំឱ្យមានការបកប្រែឯកសារនានាដែលបានដាក់បង្ហាញដោយអយ្យការទៅជាភាសាបារាំង ដែលជាភាសាផ្លូវការមួយរបស់តុលាការ ICC ដែលគាត់យល់បាន[55] ។ នៅក្នុងសេចក្តីសម្រេចដែលធ្វើការបដិសេធលើសំណើនេះ តុលាការ ICC បានពិចារណាថា ទោះបីមេធាវីការពារក្តីរបស់ចុងចោទត្រូវបានគេដាក់លក្ខខណ្ឌតម្រូវថាត្រូវតែចេះភាសាមួយនៃភាសាផ្លូវការរបស់តុលាការឱ្យបានស្ទាត់ជំនាញក៏ដោយ ក៏គាត់បានដាក់ញត្តិស្នើសុំទាំងពីរភាសា គឺភាសាបារាំង និងភាសាអង់គ្លេស[56] ។ ស្រដៀងគ្នានេះដែរ

---

[51] សេចក្តីសម្រេចលើករណីរបស់ Muhimana, កថាខណ្ឌទី ៣២-៣៣ ។

[52] សេចក្តីសម្រេចលើករណីរបស់ Muhimana, កថាខណ្ឌទី ៣១ ។

[53] សេចក្តីសម្រេចលើករណីរបស់ Muhimana, កថាខណ្ឌទី ៣២-៣៣ ។

[54] សេចក្តីសម្រេចលើករណីរបស់ Muhimana, កថាខណ្ឌទី ៣៣ ។

[55] សេចក្តីសម្រេចលើករណីរបស់ Lubanga, ទំព័រទី ២, ៤ ។

[56] សេចក្តីសម្រេចលើករណីរបស់ Lubanga, ទំព័រទី ៤ ។

នៅក្នុងករណី *Ljubicic,* តុលាការ ICTY បានសម្រេចថា ទោះបីចុងចោទមិនអាចយល់បាន លើឯកសារទាំងអស់នៅក្នុងករណីនេះក៏ដោយ ក៏"យ៉ាងហោចណាស់ក៏មានមេធាវីម្នាក់ក្នុង ចំណោមមេធាវីរបស់គាត់ត្រូវបានគេសន្មតថា បានចេះយ៉ាងស្ទាត់ជំនាញនៅលើភាសាមួយ ក្នុងចំណោមភាសាផ្លូវការនានារបស់តុលាការ ហើយគួរតែមានសមត្ថភាពចូលរួមយ៉ាងពេញ លេញនៅក្នុងដំណើរនីតិវិធី[57] ។

*តម្រូវការនៃកិច្ចសហការរវាងមេធាវីការពារក្តី ដើម្បីដោះស្រាយលើការលំបាកខាងផ្នែកភាសា*

២៤. វិធាន ២២.១ ចែងថា ចុងចោទទាំងអស់នៅចំពោះមុខតុលាការនេះ ត្រូវមានសិទ្ធិទទួលបាន ជំនួយពីមេធាវីជាតិ ឬអន្តរជាតិ "ដោយសហការជាមួយ" មេធាវីជាតិ ។

២៥. នៅក្នុងករណីរបស់ *Muhimana,* ដូចបានលើកឡើងខាងលើ តុលាការ ICTY បានពិចារណា ពីលទ្ធភាព របស់មេធាវីម្នាក់ក្នុងការយល់ដឹងអំពីភាសាទាំងពីរ៖ ភាសាបារាំង និងភាសា អង់គ្លេស ដែលពាក់ព័ន្ធនឹងសេចក្តីសម្រេចរបស់ខ្លួន ចំពោះអ្វីដែលមាននៅក្នុងការបកប្រែ ជាភាសាបារាំង ដើម្បីផ្តល់ជូនមេធាវីការពារក្តីម្នាក់ផ្សេងទៀត ។ តុលាការ ICTY បានលើក ទឹកចិត្តឲ្យមេធាវីការពារក្តីសហការគ្នាដើម្បីបានយល់ទៅលើឯកសារនានា ហួសពីមូលដ្ឋាន ដែលបានកំណត់នៅក្នុងការងារបកប្រែ ។ នៅក្នុងករណី *ខៀវ សំផន* អង្គបុរេជំនុំជម្រះនេះ បានជូនយោបល់ថាប្រសិនបើមេធាវីអន្តរជាតិរបស់ចុងចោទរូបនេះមិនអាចធ្វើការងារជាមួយ សហមេធាវីកម្ពុជារបស់ខ្លួននៅលើបញ្ហានៃការបកប្រែបានទេ នោះដំណោះស្រាយរបស់ចុង ចោទគឺជាលទ្ធភាពរបស់គាត់ក្នុងការជ្រើសរើសមេធាវីការពារក្តីអន្តរជាតិម្នាក់ផ្សេងបាន[58] ។

[57] សេចក្តីសម្រេចលើករណីរបស់ Ljubicic, ទំព័រទី ៣ ។

[58] សេចក្តីសម្រេចលើសំណើសុំពន្យារពេលសវនាការរបស់ ខៀវ សំផន, កថាខណ្ឌទី ១២ ។

00212472



## ៥. សេចក្តីសំអាង

*បណ្តឹងឧទ្ធរណ៍មិនអាចទទួលយកបានទេ*

២៦. វិធាន ៧៤.៣ បានរៀបរាប់គ្មានសល់នូវប្រភេទដីកាដែលជនត្រូវចោទអាចធ្វើបណ្តឹងឧទ្ធរណ៍ប្រឆាំងបាន ទៅអង្គបុរេជំនុំជម្រះ ។ វិធាននេះ មិនបានគិតទុកជាមុនអំពីបណ្តឹងឧទ្ធរណ៍ណាមួយ ប្រឆាំងនឹងដីកាណាមួយដែលបដិសេធសំណើសុំការបកប្រែឯកសារ ទៅជាភាសារបស់ជនត្រូវចោទ ឬរបស់មេធាវីការពារក្តីរបស់ខ្លួននោះឡើយ ។ ហេតុដូច្នេះ បណ្តឹងឧទ្ធរណ៍របស់ជនត្រូវចោទមិនអាចទទួលយកបានទេ និងគួរតែបានបដិសេធចោល ។

២៧. ចរិតលក្ខណៈដែលរៀបរាប់ទាំងអស់នៃវិធាន ៧៤.៣ នេះ ត្រូវបានលើកយកមកបង្ហាញដូចខាងក្រោម ៖

i. ការអានជាធម្មតានៅលើ ផ្នែក ឃ នៃវិធាននេះបង្ហាញឲ្យឃើញថា យុត្តាធិការដ៏ចំបងរបស់អង្គបុរេជំនុំជម្រះ គឺដើម្បីកាត់សេចក្តីវិវាទរវាងសហព្រះរាជអាជ្ញា និងសហចៅក្រមស៊ើបអង្កេត[59] ។ កិច្ចព្រមព្រៀង និងច្បាប់ អ.វ.ត.ក បានគិតទុកជាមុននៅលើបញ្ហានេះថាជា មុខងារតែមួយគត់របស់អង្គបុរេជំនុំជម្រះ[60] ។ វិធាន ៧៣ មានចែងអំពី “យុត្តាធិការបន្ថែម” របស់អង្គបុរេជំនុំជម្រះ និងបញ្ជាក់យ៉ាងច្បាស់ក្នុងការកម្រិតឲ្យនៅត្រឹមតែអ្វីៗដែលមានចែងនៅក្នុងនោះតែប៉ុណ្ណោះ ។

ii. ចំណងជើងនៃវិធាន ៧៤ *មូលដ្ឋាននៃបណ្តឹងឧទ្ធរណ៍* គឺបានពន្យល់ខ្លួនឯងរួចស្រេចហើយ ដែលវាបង្ហាញឲ្យឃើញថា មានតែដីកាដែលបានរៀបរាប់នៅក្នុងវិធាននេះតែប៉ុណ្ណោះដែលអាចប្តឹងឧទ្ធរណ៍ចំពោះមុខអង្គបុរេជំនុំជម្រះ ។ ដូចដែលវាអនុញ្ញាតឲ្យសហព្រះរាជអាជ្ញាអាចប្តឹងឧទ្ធរណ៍បានលើ *គ្រប់* ដីកាទាំងអស់របស់សហចៅក្រម

---

[59] វិធាន ៧១-៧២ នៃវិធានផ្ទៃក្នុង ។

[60] មាត្រា ៧ នៃកិច្ចព្រមព្រៀង ។ មាត្រា ២០(ថ្មី) ២៣(ថ្មី) នៃច្បាប់ អ.វ.ត.ក ។

ស៊ើបអង្កេត ប៉ុន្តែវាដាក់កម្រិតទៅលើសិទ្ធិប្ដឹងឧទ្ធរណ៍របស់ជនត្រូវចោទ បានចំពោះតែដីកាទាំងឡាយដែលមានចែងនៅក្នុងវិធាន ៧៤.៣ តែប៉ុណ្ណោះ ។

iii. វិធាននេះ មិនបានផ្ដល់យុត្តាធិការដែលសេសសល់បន្តិចណាសោះសំរាប់អង្គបុរេជំនុំជម្រះ ដែលនៅក្នុងនោះមិនបានផ្ដល់អំណាចចម្រុះ (ដូចជាតុលាការកំពូលថ្នាក់ជាតិ) ដល់អង្គជំនុំជម្រះនេះ ដើម្បីស្ដាប់សវនាការលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្ដីសម្រេចណាមួយរបស់សហចៅក្រមស៊ើបអង្កេត ដែលមានការពេញចិត្តដោយភាគីណាមួយនោះទេ ។

២៨. ស្រដៀងគ្នានេះដែរ មាត្រា ២៦៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា បានចែងដាក់កម្រិតអំពីសិទ្ធិប្ដឹងឧទ្ធរណ៍ទៅលើសេចក្ដីសម្រេចរបស់ចៅក្រមស៊ើបអង្កេត។ មាត្រានេះ មិនបានគិតទុកអំពីបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាណាមួយ ដែលបដិសេធការបកប្រែឯកសារទៅជាភាសារបស់ចុងចោទ ឬរបស់មេធាវីចុងចោទឡើយ ។

២៩. ដើមបណ្ដឹងឧទ្ធរណ៍អះអាងថា ការបដិសេធចំពោះការបកប្រែឯកសារនានា គឺវាស្មើនឹងការច្រានចោលសកម្មភាពស៊ើបសួរដោយសហចៅក្រមស៊ើបអង្កេត និងថាបើដូច្នេះ គេអាចប្ដឹងឧទ្ធរណ៍បាន ទៅតាមវិធាន ៧៤.៣.ខ ។

៣០. ការស្វែងរកការបកប្រែឯកសារគឺមិនឈានទៅដល់ការស្វែងរកសកម្មភាពស៊ើបសួរនោះទេ ។ ទោះបីជា "សកម្មភាពស៊ើបសួរ" មិនត្រូវបានគេកំណត់និយមន័យច្បាស់លាស់នៅក្នុងលិខិតុបករណ៍របស់តុលាការនេះក៏ដោយ ក៏វិធាន ៥៥.៥ បានផ្ដល់នូវបញ្ជីចង្អុលបង្ហាញមួយទាក់ទងនឹងសកម្មភាពនានាដែលត្រូវធ្វើដោយសហចៅក្រមស៊ើបអង្កេត រួមមាន៖ ក) កោះហៅ ឬសួរចម្លើយជនសង្ស័យ និងជនត្រូវចោទ ស្ដាប់ចម្លើយជនរងគ្រោះ និងសាក្សី និងកត់ត្រាទុកនូវចម្លើយរបស់ពួកគេ ប្រមូលវត្ថុតាង ស្វែងរកមតិយោបល់ពីអ្នកជំនាញ និង ដឹកនាំការស៊ើបសួរចុះដល់ទីកន្លែងកើតហេតុ, ខ) ផ្ដល់សុវត្ថិភាព និងគាំទ្រដល់សាក្សីសំខាន់ៗ និងប្រភពដទៃ

00212474

A 190/II/5



ទៀត, គ) ស្វែងរកព័ត៌មាន និងជំនួយពីរដ្ឋណាមួយ, ឃ) តាមការចាំបាច់ចេញដីកានានា ដើម្បីបំពេញកិច្ចស៊ើបសួរ ដូចជាដីកាបង្គាប់ឲ្យចូលខ្លួន ដីកាបង្គាប់ឲ្យនាំខ្លួន ដីកាបង្គាប់ឲ្យឃុំខ្លួន និងដីកាបង្គាប់ឲ្យចាប់ខ្លួន[61] ។

៣១. សេចក្តីសម្រេចលើសំណើសុំការបកប្រែ មិនចូលក្នុងសកម្មភាពទាំងអស់នេះទេ ហេតុដូចនេះ គេមិនអាចពិពណ៌នាថាជាសកម្មភាពស៊ើបអង្កេតរបស់សហចៅក្រមស៊ើបអង្កេតបានឡើយ ។ តាមពិតទៅ មិនមែនគ្រប់សកម្មភាពទាំងអស់ដែលបានធ្វើដោយសហចៅក្រមស៊ើបអង្កេត សុទ្ធតែស្ថិតក្នុងប្រភេទស៊ើបសួរនោះដែរ ។ ឧទាហរណ៍ វិធាន ៧៤.៣ និយាយពីសេចក្តីសម្រេចទាក់ទិននឹងយុត្តាធិការនិងការឃុំខ្លួនបណ្តោះអាសន្នរបស់សហចៅក្រមស៊ើបអង្កេត ។ សេចក្តីសម្រេចទាំងនេះ (ឬ"សកម្មភាព") មិនមែនជាប្រភេទនៃ"កិច្ចស៊ើបសួរ" ឡើយ[62] ។

៣២. សរុបសេចក្តីមក បញ្ហាទាក់ទិននឹងការបកប្រែ ទោះបីស្ថិតនៅក្រោមដែនកម្មសិទ្ធិនៃការធ្វើសេចក្តីសម្រេចចិត្តរបស់សហចៅក្រមស៊ើបអង្កេតក៏ដោយ ប៉ុន្តែវាមិនមែនជាប្រភេទនៃកិច្ចស៊ើបសួរនោះទេ ។ ដូច្នេះ គឺមិនអាចប្តឹងឧទ្ធរណ៍បានឡើយ ។ ការបកប្រែគឺជាកិច្ចការរបស់រដ្ឋបាលតុលាការ ស្ថិតនៅក្នុងវិសាលភាពដែលថាអ្នកគ្រប់គ្រងបញ្ជីនៅបណ្តាតុលាការអន្តរជាតិខ្លះត្រូវគ្រប់គ្រងលើកិច្ចការនេះ[63] ។ ជាលទ្ធផល បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចស្តីពីការបកប្រែ គឺច្បាស់ណាស់ថាវាហួសពីវិសាលភាពនៃវិធាន ៧៤.៣ ហេតុដូច្នេះ គឺគេត្រូវតែបដិសេធចោល ដោយសារវាមិនអាចទទួលយកបាន ។

*ឯកសារទាំងអស់នៅក្នុងសំណុំរឿងមិនត្រូវបានតម្រូវឲ្យបកប្រែ*
*ទៅជាភាសារបស់ជុងចោទនោះទេ*

[61] វិធាន ៥៥.៥ នៃវិធានផ្ទៃក្នុង ។

[62] វិធាន ៧៤.៣ នៃវិធានផ្ទៃក្នុង ។

[63] សេចក្តីសម្រេចលើករណីរបស់ Muhimana, កថាខណ្ឌទី ១០, ១៣ ។

៣៣. ដើមបណ្តឹងឧទ្ធរណ៍លើកឡើងថា ការណ៍ដែលមិនផ្តល់ឲ្យទៅគាត់នូវឯកសារដែលនៅក្នុងសំណុំរឿងទាំងអស់ជាភាសាខ្មែរដែលគាត់អាចយល់ គឺសេចក្តីសម្រេចស្តីពីការបកប្រែនោះបានរំលោភលើសិទ្ធិក្នុងការចូលរួមនៅក្នុងការការពារក្តីរបស់គាត់ ។ សហព្រះរាជអាជ្ញាសន្និដ្ឋានថា ការលើកឡើងតវ៉ាជំទាស់នោះគឺមិនមានមូលដ្ឋានខាងអង្គហេតុ និងអង្គច្បាប់ត្រឹមត្រូវទេ ។

៣៤. ទី១ គឺភាសាខ្មែរមិនមែនជាភាសាតែមួយគត់ដែលដើមបណ្តឹងឧទ្ធរណ៍អាចយល់បាននោះទេ។ បើគាត់មិនស្ទាត់ជំនាញជាងនេះទេនោះ ក៏គាត់នៅមានភាពស្ទាត់ជំនាញប្រហាក់ប្រហែលគ្នាខាងភាសាបារាំងដែរ ដែលគាត់បានសិក្សាក្នុងនាមជានិស្សិតមួយរូបដែលបាននិយាយ និងសរសេរក្នុងឋានៈរបស់គាត់ជាមន្ត្រីជាន់ខ្ពស់បំផុតមួយរូបដែលតំណាងឲ្យ *ខ្មែរក្រហម* ចាប់តាំងពីមុនពេល ក្នុងពេល និងក្រោយពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ មានអ្នកជំនាញឯកទេសខាងពេទ្យជនជាតិបារាំងមួយរូបដែលបានមកពិនិត្យអំពីនីតិសម្បទារបស់គាត់ ដើម្បីចូលរួមក្នុងសវនាការបានសរសេរនៅក្នុងកំណត់ហេតុស៊ើបសួរថា ដើមបណ្តឹងឧទ្ធរណ៍បានឆ្លើយទៅនឹងសំនួររបស់គាត់ជាភាសាបារាំងយ៉ាងស្ទាត់[64] ។

៣៥. ទី២ គឺដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមមកទល់ពេលនេះមានត្រៀមជាភាសាខ្មែររួចជាស្រេចហើយសម្រាប់ដើមបណ្តឹងឧទ្ធរណ៍ ។ សហចៅក្រមស៊ើបអង្កេត បានចេញដីកាសម្រេចរួចហើយឲ្យបកប្រែជាភាសាខ្មែរនូវរាល់លេខយោងជើងទំព័រ និងរាល់សញ្ញាបង្ហាញអំពីធាតុផ្សំខាងអង្គហេតុទាំងអស់ ដែលបានភ្ជាប់នៅក្នុងនោះឲ្យទៅជាភាសាខ្មែរ ។ លើសពីនេះ ឯកសារភស្តុតាងភាគច្រើនដែលបានបង្កើតទៅជាផ្នែកនៃសេចក្តីសន្និដ្ឋានទាំងនោះ ដែលរួមមានចម្លើយសាក្សីភាគច្រើនត្រូវបានធ្វើជាកំណត់ហេតុ និងពាក្យបណ្តឹងនានារបស់ជនរងគ្រោះដែលបានទទួលមក ត្រូវបានធ្វើឲ្យទៅជាភាសាខ្មែរ និង/ឬ ជាភាសាបារាំង ។

---

[64] *ករណីរបស់ អៀង សារី,* របាយការណ៍របស់អ្នកជំនាញការ, សំណុំរឿងព្រហ្មទណ្ឌលេខៈ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស ចុះថ្ងៃទី១៤ ឧសភា ២០០៨, លេខERN 00189152-00189176, D76/IV, ទំព័រទី ៥ ។

៣៦. ទី៣ គឺបន្ទាប់ពីការចាប់ផ្តើមកិច្ចស៊ើបសួរ ឯកសារភស្តុតាងស្ទើរតែទាំងអស់ ដែលបង្កើតឡើងដោយការិយាល័យសហចៅក្រមស៊ើបអង្កេត ដែលរួមមាន កម្រងឯកសារភស្តុតាង និងភស្តុតាងជាសក្ខីកម្មគឺសុទ្ធតែជាភាសាខ្មែរ និង/ឬ ភាសាបារាំងស្រាប់ ។ និន្នាការដដែលនេះត្រូវបានរំពឹងទុកថានឹងបន្តធ្វើនៅក្នុងពេលអនាគត ។

៣៧. ទី៤ គឺសេចក្តីណែនាំអនុវត្តតម្រូវឲ្យរាល់សារណាទាំងអស់ដែលដាក់ជូនចំពោះមុខតុលាការនេះយ៉ាងហោចណាស់ក៏ត្រូវធ្វើជាភាសាខ្មែរដែរ ។ សហចៅក្រមស៊ើបអង្កេត និងអង្គបុរេជំនុំជម្រះបានអនុម័តនូវការចេញសេចក្តីសម្រេចនានារបស់ខ្លួនជាភាសាខ្មែរ និងយ៉ាងហោច ជាភាសាផ្សេងមួយទៀតដែរ ។

៣៨. ទី៥ គឺកិច្ចព្រមព្រៀងស្តីពីបង្កើតតុលាការនេះ និងវិធាននានា តម្រូវឲ្យក្រុមមេធាវីការពារក្តីតំណាងឲ្យចុងចោទ[65] លើកឡើងឲ្យពេញលេញអំពីបញ្ហាផ្សេងៗខាងភាសាសាស្ត្រ និងខាងអង្គច្បាប់ ។ ស្របគ្នានេះដែរ ដើមបណ្តឹងឧទ្ធរណ៍ត្រូវបានផ្តល់ជូននូវមេធាវីអន្តរជាតិមួយរូបដែលបានធ្វើការងារដោយរួមសហការគ្នាជាមួយក្រុមមេធាវីខ្មែររបស់គាត់ ។ មេធាវីការពារក្តីខ្មែរបច្ចុប្បន្នរបស់ចុងចោទ អាចយល់ភាសាខ្មែរ និងភាសាអង់គ្លេសបានដោយសារបទពិសោធន៍ដ៏ច្រើនរបស់គាត់ ដែលធ្លាប់ធ្វើការងារជាមួយអង្គការក្រៅរដ្ឋាភិបាលដ៏ល្បីឈ្មោះមួយដែលមានមូលដ្ឋាននៅក្នុងទីក្រុងភ្នំពេញ ។ ជាទម្លាប់រៀងមក គាត់ធ្លាប់បានចុះហត្ថលេខា និងដាក់ឯកសារតែម្នាក់ឯងគត់តំណាងឲ្យដើមបណ្តឹងឧទ្ធរណ៍រូបនេះ ជាភាសាអង់គ្លេស ។ មេធាវីការពារក្តីអន្តរជាតិរបស់ដើមបណ្តឹងឧទ្ធរណ៍និយាយភាសាអង់គ្លេស ហើយក៏ធ្លាប់មានបទពិសោធន៍យ៉ាងទូលំទូលាយធ្វើការងារនៅក្នុងប្រទេសកម្ពុជា ជាពិសេសក្នុងផ្នែកការពារសិទ្ធិ ។ ដើមបណ្តឹងឧទ្ធរណ៍មានមេធាវីខ្មែរមួយរូបបន្ថែមទៀត ដែលធ្វើការងារជាអ្នកគ្រប់គ្រងសំណុំរឿង ក៏និយាយនិងយល់ភាសាខ្មែរ និងភាសាអង់គ្លេសដោយងាយស្រួលដែរ ។ បន្ថែមលើនេះ ក្រុមអ្នកច្បាប់របស់ដើមបណ្តឹងឧទ្ធណ៍រួមមាន មេធាវីជនជាតិអង់គ្លេសម្នាក់

[65] សេចក្តីសម្រេចទាក់ទងនឹងការបកប្រែ, ទំព័រទី ៣ ។

ដែលត្រូវបានឲ្យទៅធ្វើការនៅសមាគមមេធាវីអាមេរិកកាំង ក៏ធ្លាប់បានការពារក្នុងរឿងក្ដីអន្តរជាតិ ពីបទឧក្រិដ្ឋកម្មសង្គ្រាមដ៏ស្មុគ្រស្មាញនៅចំពោះមុខតុលាការ ICTY និងតុលាការ ICC ។ មានមេធាវីម្នាក់ទៀត ដែលទើបតែបានចូលរួមនៅក្នុងក្រុមមេធាវីការពារក្ដីរបស់ដើមបណ្ដឹងឧទ្ធរណ៍ ក្នុងឋានៈជាអ្នកហាត់ការរយៈពេលយូរ ។ ក្នុងចំណោមពួកមេធាវីការពារក្ដីជាតិ និងអន្តរជាតិទាំងនេះ សុទ្ធតែអាចសហការគ្នាដើម្បី“ធ្វើឲ្យសមត្ថភាពខាងភាសាសាស្ត្រនៃការិយាល័យរបស់ពួកគេមានលក្ខណៈល្អប្រសើរបំផុត” ដើម្បីអាចដោះស្រាយចំពោះកង្វល់ផ្សេងៗរបស់ដើមបណ្ដឹងឧទ្ធរណ៍ ដែលនៅក្នុងសំណុំរឿងមិនមានឯកសារជាភាសាខ្មែរ ដែលគាត់អាចបើកមើលបាន[66] ។ លើសពីនេះ ដើមបណ្ដឹងឧទ្ធរណ៍បានរក្សាទុកលោកសាស្ត្រាចារ្យ Michael Vickery ឲ្យនៅបំរើការងារនៅក្នុងក្រុមមេធាវីការពារក្ដីរបស់គាត់ដដែល ដែលគាត់មិនគ្រាន់តែអាចនិយាយ សរសេរ និងយល់ភាសាខ្មែរបានដោយងាយស្រួល ដូចគ្នាប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជាអ្នកដែលមានប្រភពចំណេះដឹងដែលគេទទួលស្គាល់ទៀតផងអំពីប្រវត្តិសាស្ត្រខ្មែរ និងអំពីរយៈកាលនៃរបបកម្ពុជាប្រជាធិបតេយ្យ ។

៣៩. ទី៦ គឺរហូតមកទល់នឹងពេលធ្វើវិសោធនកម្មលើសេចក្ដីណែនាំអនុវត្ត ខែមេសា ឆ្នាំ២០០៨ នោះគឺភាសាអង់គ្លេស (មិនមែនភាសាខ្មែរទេ) ដែលជាភាសាតែមួយគត់ដែលត្រូវបានចូលចិត្តប្រើនៅក្នុងការដាក់ និងការទទួលឯកសារផ្សេងៗរបស់ក្រុមមេធាវីការពារក្ដីរបស់ដើមបណ្ដឹងឧទ្ធរណ៍ ។ នេះគឺជាការបង្ហាញថា ដើមបណ្ដឹងឧទ្ធរណ៍ និងក្រុមមេធាវីការពារក្ដីរបស់គាត់គឺមានសមត្ថភាពពេញលេញ - ឬមានសមត្ថភាពខាងភាសាសាស្ត្រគ្រប់គ្រាន់ក្នុងការ - អាន សរសេរ និងយល់ អំពីឯកសារច្បាប់ និងឯកសារភស្តុតាងនានាជាភាសាអង់គ្លេសតែមួយប៉ុណ្ណោះ ហើយដូចនេះគឺមិនបានតម្រូវអំពីឯកសារជាភាសាខ្មែរទេ ។

៤០. ទី៧ ឯកសារទាំងឡាយដែលមានស្រាប់ជាភាសាខ្មែរ និងឯកសារដែលត្រូវបានបង្គាប់ឲ្យផ្ដល់មកឲ្យជាភាសាខ្មែរនៅក្នុងសេចក្ដីសម្រេចទាក់ទងនឹងការបកប្រែ បានផ្ទុះបញ្ចាំងពីរបបក្នុងការដាក់បង្ហាញឯកសារមួយដែលមានលក្ខណៈសេរីបំផុត ដែលតុលាការ ICTY និង

[66] សេចក្ដីសម្រេចទាក់ទងនឹងការបកប្រែ, កថាខណ្ឌ A4 ។

តុលាការ ICTR បានប្រកាន់យក ។ ឯកសារជាមូលដ្ឋានទាំងឡាយរបស់តុលាការ ICC ដែលត្រូវបានព្រាងក្នុងពេលក្រោយមកទៀត. និងកំពុងរួមបញ្ចូលនូវច្បាប់អន្តរជាតិដ៏ជាក់លាក់ស្តីពីបញ្ហាទាំងនោះ - ទោះបីជាមានភាពច្បាស់ជាងក៏ដោយ ក៏នៅមានការរឹតត្បឹតជាង ។ ក្រៅពីឯកសារចំបងមួយប្រភេទនោះ តុលាការ ICC បានអនុម័តនូវគោលការណ៍បន្ថែមស្តីពីសមត្ថភាពខាងភាសាសាស្ត្រដល់ក្រុមមេធាវីការពារក្តីនានា ដើម្បីធានាថាចុងចោទអាចចូលរួមដោយប្រសិទ្ធិភាពនៅក្នុងការការពារក្តីរបស់ខ្លួនផ្ទាល់ ។ សហចៅក្រមស៊ើបអង្កេត បានអនុម័តនូវវិធីសាស្ត្រកូនកាត់មួយនៃវិធីសាស្ត្រទាំងពីរនេះ ដែលមិនធ្វើឲ្យខូចដល់សិទ្ធិទទួលបានការជំនុំជម្រះក្តីដោយត្រឹមត្រូវណាមួយរបស់ចុងចោទនោះទេ ។

៤១. ទី៨ គឺនៅពេលដែលសហចៅក្រមស៊ើបអង្កេត បានចេញសេចក្តីសម្រេចឲ្យផ្តល់ឯកសារឯកសារចំបងមួយប្រភេទ ជាភាសាដែលជនត្រូវចោទអាចយល់បាននោះ សហចៅក្រមស៊ើបអង្កេត មិនបានហាមឃាត់ក្រុមមេធាវីការពារក្តី មិនឲ្យស្នើសុំការបកប្រែឯកសារបន្ថែមទៀតពីផ្នែកគ្រប់គ្រងតុលាការ ដោយផ្អែកលើមូលដ្ឋាននៃបញ្ជីរួម និងការកំណត់អាទិភាពឯកសារដែលអ្នកស្នើសុំចំនួនច្រើនតម្រូវឲ្យបានឆាប់បំផុតនោះទេ ។ តាមពិត ក្រុមការងារបកប្រែដែលក្នុងនោះរួមមាន តំណាងរបស់អង្គភាពគាំទ្រការការពារក្តីមួយរូបផងជួបប្រជុំគ្នា និងធ្វើសកម្មភាពនៅក្នុងការសន្ទតនេះ។

៤២. ដើមបណ្តឹងឧទ្ធរណ៍ បានចោទសួរអំពីការប្រើយុត្តិសាស្ត្ររបស់តុលាកាr ICTY ICTR និង ICC នៅក្នុងដំណើរការនីតិវិធីនៅចំពោះមុខតុលាការនេះ ដោយផ្អែកលើហេតុផលថា ប្រព័ន្ធច្បាប់ ទាំងពីរនេះខុសគ្នា ។ គាត់បានទាមទារថា នៅចំពោះមុខតុលាការនេះមានចុងចោទមួយរូបចូលរួមនៅក្នុងដំណើរការនីតិវិធី តាំងពីយូរមុនពេលគាត់ចូលរួមនៅក្នុងតុលាការផ្សេងទាំងនោះទៅទៀត ហេតុដូច្នេះហើយ សិទ្ធិក្នុងការប្រើប្រាស់សេវាបកប្រែ ត្រូវតែបានផ្តល់ឲ្យនៅក្នុងដំណាក់កាលតាំងពីយូរមុននេះមកម្ល៉េះ ដោយរួមទាំងសិទ្ធិក្នុងការពិនិត្យមើលភស្តុតាងដោះបន្ទុកផង ដើម្បីធ្វើឲ្យគាត់អាចមានលទ្ធភាពចូលរួមនៅក្នុងការស៊ើបសួរបានដោយប្រសិទ្ធិភាព ។ សហព្រះរាជអាជ្ញា ធ្វើការកត់សំគាល់ថា នៅពេលដែលអាចនឹងមានការខុស

គ្នាជាលក្ខណៈប្រព័ន្ធនោះ ដំណោះស្រាយតាមផ្លូវច្បាប់ដែលត្រូវបានកំណត់ដោយវិធាននានា និងដែលត្រូវបានបញ្ជាក់នៅក្នុងដីកាសម្រេចស្តីពីការបកប្រែ បានធ្វើឱ្យកើតមាននូវការខុសគ្នាទាំងនោះ បើសិនជាមានការខុសគ្នាណាមួយដែលមិនមានផលវិបាក ។ នៅពេលដែលមានការពិតថា ក្នុងពេលភ្លាមៗបន្ទាប់ពីចូលរួមនៅក្នុងកិច្ចស៊ើបសួរ នៅក្នុងពេលសវនាការដេញដោល ចុងចោទត្រូវបានអញ្ជើញឱ្យដាក់សារណាអំពីភស្តុតាងសំខាន់ៗនោះ សិទ្ធិពិនិត្យមើលឯកសាររបស់គាត់អាចនឹងត្រូវបានបង្កលក្ខណៈងាយស្រួល ដោយសារកិច្ចសហការក្នុងរង្វង់ក្រុមមេធាវីរបស់គាត់ និងដោយសារការជួយឧបត្ថម្ភពីផ្នែកគាំពារការការពារក្តី ។ បន្ថែមលើនេះ មិនមានការយល់ព្រមទូលំទូលាយទៅលើសិទ្ធិក្នុងការផ្តល់ឯកសារដោះបន្ទុកជាភាសារបស់ចុងចោទនោះទេ។ នៅពេលដែលតុលាការ*ពិសេស* បានផ្តល់ឱ្យនូវឯកសារនេះ តុលាការ ICC មិនបានផ្តល់ឱ្យទេ ។

៤៣. ការជំនុំជម្រះក្តីដោយត្រឹមត្រូវយុត្តិធម៌ ដែលតម្រូវឱ្យផ្តល់ឯកសារជាភាសាដែលចុងចោទអាចយល់បាននោះគឺត្រូវបានបំពេញឱ្យបានគ្រប់គ្រាន់ដោយដំណោះស្រាយ ចំពោះសមត្ថភាពពេញលេញខាងភាសាសាស្ត្ររបស់ក្រុមមេធាវីការពារក្តី ចំពោះធនធានរបស់ផ្នែកគាំពារការការពារក្តីចំពោះអ្នកបកប្រែសរសេរធ្វើការពេញម៉ោង ដែលត្រូវបានចាត់តាំងដូចនៅក្នុងសេចក្តីសម្រេចទាក់ទងនឹងការបកប្រែភាសា និងចំពោះការខិតខំប្រឹងប្រែងរបស់ផ្នែកគ្រប់គ្រងតុលាការ (CMS) ដើម្បីផ្តល់នូវសេវាបកប្រែឯកសារឱ្យបានទាន់ពេលវេលា ។ ទោះជាយ៉ាងណាក្តី សេចក្តីសម្រេចទាក់ទងនឹងការបកប្រែ មិនបានចែងកំណត់អំពីសិទ្ធិទទួលបានការបកប្រែ និងអំពីកាតព្វកិច្ចរបស់ភាគីនានានៅគ្រប់ដំណាក់កាលទាំងអស់នៃដំណើរការនីតិវិធីនោះ ។ ក្នុងដីកាសម្រេចនោះគ្រាន់តែនិយាយថា អង្គជំនុំជម្រះសាលាដំបូង និងអង្គបុរេជំនុំជម្រះ ដែលសេចក្តីសម្រេចនោះមិនអាចភ្ជាប់កាតព្វកិច្ច អាចធ្វើសេចក្តីសម្រេចបែបដូច្នេះបានតាមការដែលពួកគេយល់ឃើញថាជាការសមស្រប ។

*សេចក្តីសម្រេចទាក់ទងនឹងការបកប្រែ បានការពារសិទ្ធិក្នុងការធ្វើតំណាងដ៏មានប្រសិទ្ធិភាពរបស់ចុងចោទ*

៤៤. ដើមបណ្តឹងឧទ្ធរណ៍បានទាមទារថា សិទ្ធិរបស់ខ្លួនដែលត្រូវតំណាងដោយមេធាវីការពារក្តីអន្តរជាតិមួយរូបដ៏មានប្រសិទ្ធិភាព ត្រូវបានរំលោភបំពាន ដោយសារតែការខកខាននៃសេចក្តីសម្រេចស្តីពីការបកប្រែ មិនបានបង្គាប់ឱ្យធ្វើការបកប្រែគ្រប់ឯកសារទាំងអស់នៅក្នុងសំណុំរឿងឱ្យទៅជាភាសាអង់គ្លេស ដែលជាភាសារបស់មេធាវីការពារក្តីអន្តរជាតិរបស់គាត់ ។ ដើមបណ្តឹងឧទ្ធរណ៍រូបនោះក៏បានជំទាស់ដែរថា ការខកខានមិនបានឱ្យធ្វើការបកប្រែនូវរាល់ឯកសារដោះបន្ទុកទាំងអស់ទៅជាភាសាអង់គ្លេស គឺរារាំងដល់ក្រុមមេធាវីការពារក្តីមិនអាចចូលរួមបានដោយប្រសិទ្ធិភាពនៅក្នុងការស៊ើបសួររបស់តុលាការ ដោយស្នើសុំឱ្យបើកកិច្ចស៊ើបសួរផ្សេងៗ ជាពិសេសនៅក្នុងដំណាក់កាលដំបូងៗនៃដំណើរការនីតិវិធី ។

៤៥. ដូចបានរៀបរាប់ខាងលើនេះ គឺជាការលំបាកនឹងមានលិខិតុបករណ៍អន្តរជាតិ ឬប្រភពច្បាប់សម្រាប់យោងណាមួយ ដែលធ្វើឱ្យតុលាការនេះត្រូវជាប់កាតព្វកិច្ចអនុវត្តតាម ដើម្បីធានាថារាល់ឯកសារទាំងអស់នៅក្នុងសំណុំរឿងរបស់ចុងចោទ ត្រូវតែបកប្រែទៅជាភាសារបស់មេធាវីការពារក្តីណាស់ ជាពិសេស គឺនៅពេលដែលរឿងនេះមិនត្រូវបានទាមទារឱ្យធ្វើទៅជាភាសារបស់ចុងចោទ ។ នៅពេលណាក៏ដោយ មិនសូវមានករណីដែលតុលាការអន្តរជាតិផ្តល់ការអនុញ្ញាតលើសំណើបែបនេះទេ តុលាការអន្តរជាតិទាំងនោះបានលើកទឹកចិត្តដល់ក្រុមមេធាវីការពារក្តីនានាឱ្យប្រើប្រាស់នូវសមត្ថភាពផ្នែកភាសាសាស្ត្រ ដែលមានស្រាប់នៅនឹងកន្លែង ដើម្បីដោះស្រាយឱ្យបានចំពោះការខ្វះខាតសមត្ថភាពខាងភាសាសាស្ត្ររបស់មេធាវីណាមួយនៅក្នុងភាសារបស់ចុងចោទ ។ សហព្រះរាជអាជ្ញា ធ្វើសេចក្តីសន្និដ្ឋានថា ដើមបណ្តឹងឧទ្ធរណ៍មិនមានសិទ្ធិបែបនេះជាប់មកជាមួយស្រាប់នោះទេ អាស្រ័យហេតុនេះ គាត់មិនអាចលើកយកសិទ្ធិនេះមកប្រើដើម្បីតវ៉ាទាមទារអំពីការមានមេធាវីតំណាង ដោយមិនមានប្រសិទ្ធិភាពបានឡើយ ។

៤៦. បណ្តឹងឧទ្ធរណ៍ខកខានមិនបានទទួលស្គាល់លក្ខណៈពិសេសរបស់តុលាការនេះដែលនៅគ្រប់ជាន់ថ្នាក់ទាំងអស់ - រួមទាំងនៅក្នុងក្រុមមេធាវីការពារក្តីផង - ដែលមានបុគ្គលិកបរទេសធ្វើ

00212481

A190/II/5



ការងារយ៉ាងជិតស្និទ្ធជាមួយបុគ្គលិកខ្មែរជាដៃគូររបស់ខ្លួន ដើម្បីជួយគាំទ្រដល់សមត្ថភាពខាងផ្នែកភាសាសាស្ត្រ និងផ្នែកច្បាប់ជាសមូហភាព ។ អាស្រ័យហេតុនេះ មេធាវីការពារក្តីអន្តរជាតិមិនធ្វើការទោលតែម្នាក់ឯងដាច់ដោយឡែកពីគេនោះទេ ។ មេធាវីការពារក្តីអន្តរជាតិត្រូវបានគេរំពឹងទុកថា គាត់ត្រូវធ្វើការងារដោយសហការគ្នាជាមួយនឹងមេធាវីការពារក្តីខ្មែរ ហើយត្រូវប្រើប្រាស់នូវសមត្ថភាពខាងផ្នែកភាសាសាស្ត្រតាមដូចដែលបានចែង និងត្រូវត្រៀមឲ្យមានសមត្ថភាពដូចនេះជាស្រេចសម្រាប់ក្រុមមេធាវីការពារក្តី ។ តាមពិត សេចក្តីសម្រេចទាក់ទងនឹងការបកប្រែនោះ គឺបានជួយគាំទ្រចំពោះសមត្ថភាព ខាងផ្នែកភាសាសាស្ត្រនេះដោយការ ផ្តល់ជូនបន្ថែមដល់ក្រុមមេធាវីការពារក្តីនីមួយៗនូវអ្នកបកប្រែសរសេរ ដែលផ្តល់ជូនសម្រាប់តែការងារបកប្រែ ។

៤៧. ថ្វីត្បិតតែមានការខ្វះខាតក្នុងការទទួលស្គាល់សិទ្ធិត្រូវមានឯកសារនានា ជាភាសារបស់មេធាវីការពារក្តីអន្តរជាតិក៏ដោយ ក៏នៅពេលដែលគាត់មិនចេះនិយាយភាសារបស់ចុងចោទនោះ សេចក្តីសម្រេចទាក់ទងនឹងការបកប្រែនេះ បានព្យាយាមឲ្យបង្កើតជាយន្តការមួយ សម្រាប់ក្រុមមេធាវីការពារក្តីនានាដើម្បីទទួលបានសេវាបកប្រែភ្លាមៗនូវឯកសារនានាឲ្យទៅជាភាសាផ្សេងៗក្រៅពីភាសាខ្មែរ ។ សេចក្តីសម្រេចនេះ បានចែងអំពីតម្រូវការបុគ្គលិកបន្ថែមដែលត្រៀមសម្រាប់តែបកប្រែដើម្បីធានាឲ្យប្រាកដថាឯកសារអ្វីក៏ដោយដែលត្រូវឲ្យធ្វើការបកប្រែជាប្រញ៉ាប់ ឬដោយឥតបានព្រាងទុក អាចមាននៅនឹងកន្លែងស្រាប់ ដោយសារមានជំនួយពីពួកអ្នកបកប្រែសរសេរដោយមិនគិតកម្រៃដែលមានស្រាប់នៅនឹងកន្លែង ។

*ដីកាសម្រេចស្តីពីការបកប្រែបានធានាឲ្យប្រាកដនូវគោលការណ៍អំពីកម្លាំងស្មើគ្នា*

៤៨. ដើមបណ្តឹងឧទ្ធរណ៍បានតវ៉ាជំទាស់ថា ដីកាសម្រេចស្តីពីការបកប្រែបានព្យាយាមធ្វើការផ្ទេរគោលការណ៍ស្តីពីកម្លាំងស្មើគ្នា (to shift the equality of arms) ដោយដាក់បន្ទុកក្នុងការបកប្រែទៅលើមេធាវីការពារក្តីទៅវិញ ហេតុដូចនេះ គឺចេញផុតពី “សមត្ថកិច្ចរបស់រដ្ឋ” ដែលជាធម្មតាគឺរដ្ឋជាអ្នកត្រូវផ្តល់នូវសេវាបកប្រែនេះ ។

៤៩. ដោយសារក្នុងការផ្តល់អ្នកបកប្រែសរសេរមួយរូបជាក់លាក់សម្រាប់ក្រុមមេធាវីការពារក្តីនីមួយៗនោះ ដីកាសម្រេចស្តីពីការបកប្រែ មិនបានខិតខំដើម្បីផ្ទេរបន្ទុកក្នុងការបកប្រែទៅឲ្យក្រុមមេធាវីការពារក្តីនោះទេ ។ តាមពិត ការផ្តល់បន្ថែមនូវធាតុបករណ៍ជំនួយបន្ថែមនេះ មិនបានបង្កើតនូវកាតព្វកិច្ចថ្មីណាមួយទៅឲ្យមេធាវីការពារក្តីនោះទេ ក៏ប៉ុន្តែខំស្វែងរកការបំពេញបន្ថែមទៅលើសមត្ថភាពខាងភាសាសាស្ត្រដែលមានស្រាប់តែប៉ុណ្ណោះ ដើម្បីនឹងជួយលើកស្ទួយថែមទៀតដល់សិទ្ធិរបស់ចុងចោទក្នុងការមានមេធាវីតំណាងដោយប្រសិទ្ធិភាព។ ដីកាសម្រេចស្តីពីការបកប្រែ បានបញ្ជាក់យ៉ាងច្បាស់ថា គោលបំណងនៃវិធានការនេះ គឺ "ដើម្បីធ្វើឲ្យប្រាកដថា ជនត្រូវចោទ និងក្រុមមេធាវីការពារក្តីរបស់គេអាចមានឯកសារដែលបានបកប្រែរួចជាស្រេចមួយចំនួនតាមតម្រូវការ ដើម្បីវាយតម្លៃអំពីតម្រូវការក្នុងការបកប្រែរបស់ក្រុមមេធាវីការពារក្តីដែលត្រូវបញ្ជូនទៅឲ្យផ្នែកគ្រប់គ្រងតុលាការ និងដើម្បីជួយដល់កិច្ចសហការរបស់ក្រុមមេធាវីទាំងនោះជាមួយផ្នែកគ្រប់គ្រងតុលាការ"[67] ។ អាស្រ័យហេតុនេះ បន្ទុករបស់ផ្នែកគ្រប់គ្រងតុលាការក្នុងកំរិតដែលត្រូវបានកំណត់ឲ្យទៅទាំងប៉ុន្មាននោះ គឺមិនត្រូវបានធ្វើការផ្ទេរនោះទេ ។ ផ្ទុយទៅវិញ គឺក្រុមមេធាវីការពារក្តីនឹងកាន់តែត្រូវបានពង្រឹងថែមទៀតដើម្បីឲ្យបានស្ថិតនៅក្នុងស្ថានភាពមួយដ៏ល្អប្រសើរក្នុងការប្រើប្រាស់សេវាបកប្រែរបស់ផ្នែកគ្រប់គ្រងតុលាការនោះ ។ អ្នកបកប្រែថ្មីទាំងនោះ ទំនងជានឹងជួយដល់ក្រុមមេធាវីការពារក្តីនានាផងដែរក្នុងការធានាឲ្យប្រាកដថា ធនធាននានារបស់ផ្នែកគ្រប់គ្រងតុលាការនឹងត្រូវបានគេយកទៅប្រើប្រាស់ដោយមានប្រសិទ្ធិភាព និងបានប្រសើរបំផុត និងជៀសវាងកុំឲ្យមានជាន់គ្នា ដែលជាការព្រួយបារម្ភ (សូម្បីតែការធ្វើលឿនមុនពេលកំណត់ពេកក៏ដោយ) ដ៏ស្របច្បាប់មួយ ដូចដែលបានលើកឡើងនៅក្នុងបណ្តឹងឧទ្ធរណ៍ស្រាប់ ។

៥០. សហព្រះរាជអាជ្ញា រំពឹងទុកជាមុនថា ការផ្តល់អ្នកបកប្រែឯកសារ នឹងជួយដល់ក្រុមមេធាវីការពារក្តីនានានៅក្នុងករណីដែលតម្រូវឲ្យបកប្រែ ដែលត្រូវកំណត់យកក្នុងរយៈពេលដ៏ខ្លីដោយឥតព្រាងទុកជាមុន ឬបន្ទាន់ភ្លាមៗ ។ ស្របតាមយុត្តិសាស្ត្រអន្តរជាតិ ការណ៍នេះ

[67] សេចក្តីសម្រេចរបស់ ក.ស.ច.ស, កថាខណ្ឌ E4 ។

ត្រូវបានភ្ជាប់កាតព្វកិច្ចឡើងវិញជាថ្មីទៅនឹងសិទ្ធិរបស់ចុងចោទ និងមិនត្រូវបង្កើតនូវកាតព្វកិច្ចថែមទៀតដល់ក្រុមមេធាវីការពារក្តីទេ ។

៥១. ដើមបណ្តឹងឧទ្ធរណ៍ទាមទារថា អ្នកបកប្រែសរសេរធ្វើដែលផ្តល់ឲ្យបន្ថែមនឹង "មិនជួយដល់សហមេធាវីបរទេសដែលមិនមានមូលដ្ឋាននៅទីក្រុងភ្នំពេញទេ" ។ ការវែកញែកទាញហេតុផលបែបនេះគឺខុស ។ សន្មតថា ការបកប្រែគឺអាចមានតែការបកប្រែដោយផ្ទាល់មាត់ ឬបកប្រែសរសេរតែប៉ុណ្ណោះ។ ដោយសន្មតថា អ្នកបកប្រែសរសេរទាំងនោះទទួលតែការងារបកប្រែដោយផ្ទាល់មាត់ប៉ុណ្ណោះ ហើយចុងចោទមានសិទ្ធិក្នុងការជ្រើសរើសយកមេធាវីការពារក្តីអន្តរជាតិមួយរូបដែលរស់នៅទីក្រុងភ្នំពេញ ដើម្បីធ្វើជាមេធាវីតំណាងឲ្យរូបគេកាន់តែមានប្រសិទ្ធិភាពថែមទៀត ។ គាត់បានសម្រេចចិត្តជ្រើសរើសដោយស្ម័គ្រចិត្តក្នុងការរក្សាទុកមេធាវីការពារក្តីអន្តរជាតិមួយរូបដដែល ដែលមេធាវីនេះបានសម្រេចថាមិនតាំងមូលដ្ឋានរបស់ខ្លួននៅក្នុងទីក្រុងភ្នំពេញទេ ។ មេធាវីការពារក្តីនៅចំពោះមុខតុលាការស្រដៀងគ្នានេះដែរ ត្រូវបានផ្តល់ប្រាក់បៀវត្សរ៍តាមបទដ្ឋានស្រដៀងគ្នាទៅតាមទម្លាប់ជាធម្មតាស្ថិតនៅក្នុងអាសនៈនានានៃតុលាការទាំងនោះ ដោយមានទស្សនៈមួយដើម្បីធ្វើជាអ្នកតំណាងឲ្យដើមានប្រសិទ្ធិភាពចំពោះកូនក្តីរបស់ខ្លួន ។ ចំណែកឯតុលាការនេះវិញ គឺត្រូវផ្តល់ឲ្យចុងចោទនូវសិទ្ធិ "ទទួលបាននូវធាសុបករណ៍ដើម្បីត្រៀមរៀបចំសម្រាប់ការការពារក្តីរបស់ខ្លួន" នេះគឺមិនសំដៅទៅដល់ធាសុបករណ៍ផ្សេងៗនៅទីកន្លែងណាក៏បាននៅក្នុងពិភពលោកនោះទេ ។

៥២. សេចក្តីសំអាងទាក់ទិនទៅនឹងគោលការណ៍ស្តីពីកម្លាំងស្មើគ្នា ក៏ត្រូវតែបានច្រានចោលផងដែរ ផ្អែកលើទឡ្ហីករណ៍បន្ថែម ដែលថា ដើមបណ្តឹងឧទ្ធរណ៍បានជ្រើសរើសមិនទទួលយកនូវធាសុបករណ៍ណាមួយផ្នែកគ្រប់គ្រងតុលាការ បានផ្តល់ឲ្យសម្រាប់ការបកប្រែឯកសារដើម្បីធ្វើវាឲ្យមានប្រយោជន៍ ។ ជាពិសេស ដើមបណ្តឹងឧទ្ធរណ៍ មិនបានឆ្លើយតបទៅនឹងសេចក្តីណែនាំនៅក្នុងសេចក្តីសម្រេចទាក់ទងនឹងការបកប្រែ ដែលបានស្វែងរកនូវការដាក់សារណាផ្សេងៗពីសំណាក់ក្រុមមេធាវីការពារក្តី ពាក់ព័ន្ធនឹងការដាក់អាទិភាពលើសំណើសុំការបកប្រែ ។

## ៦. សេចក្តីសន្និដ្ឋាន

៥៣. អាស្រ័យហេតុនេះ សហព្រះរាជអាជ្ញា ស្នើឲ្យ អង្គបុរេជំនុំជម្រះ បដិសេធបណ្តឹងឧទ្ធរណ៍នេះចោល ដោយហេតុថាមានកំហុសនីតិវិធី ដែលមិនអាចទទួលយកបាន និងជាសំខាន់ គឺគ្មានអង្គសេចក្តី ។

ធ្វើនៅភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
នៅថ្ងៃទី១៥ ខែសីហា ឆ្នាំ២០០៨
**សហព្រះរាជអាជ្ញា**

| | |
|---|---|
| **លោកស្រី ជា លាង** | **លោក** William SMITH |
| សហព្រះរាជអាជ្ញា | សហព្រះរាជអាជ្ញារង |